ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# រាជរដ្ឋាភិបាលកម្ពុជា



# របាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ

រៀបចំដោយ
គណៈកម្មាធិការសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា
នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
ខែមិថុនា ឆ្នាំ២០២៥

# អារម្ភកថា

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយ និងការអនុវត្ត "នយោបាយឈ្នះ-ឈ្នះ" ប្រកបដោយភាពប៉ិនប្រសប់ និងប្រាកដនិយមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**, កម្ពុជាសម្រេចបានយ៉ាងរឹងមាំនូវសន្តិភាព, អធិបតេយ្យជាតិ, ស្ថិរភាពនយោបាយ, សន្តិសុខសង្គម និងសណ្តាប់ធ្នាប់សាធារណៈ ។ លើមូលដ្ឋាននេះ, រាជរដ្ឋាភិបាលកម្ពុជាបានបន្តខិតខំប្រឹងប្រែង ហើយសម្រេចបានសមិទ្ធផលត្រចះត្រចង់ជាច្រើនក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ដោយបានជំរុញខឿនសេដ្ឋកិច្ចជាតិឱ្យមានសន្ទុះកើនឡើង, សម្រេចកំណើនសេដ្ឋកិច្ចក្នុងរង្វង់ ៧% ក្នុងរយៈពេលជាង២ទសវត្សរ៍, រក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រជាបន្តបន្ទាប់ ដែលទាំងនេះបានលើកកម្ពស់កិត្យានុភាពរបស់ព្រះរាជាណាចក្រកម្ពុជានៅលើឆាកអន្តរជាតិ ។

លើមាគ៌ានេះ រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយឈ្លាសវៃ និងថាមវន្តរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានបន្តពូនជ្រុំផ្លែផ្កានៃកិច្ចអភិវឌ្ឍន៍កន្លងមក និងសម្លឹងឆ្ពោះទៅមុខក្នុងជំហានដ៏ស្វាហាប់ និងភាពជឿជាក់ក្នុងការដោះស្រាយបញ្ហាប្រឈម និងចាប់យកកាលានុវត្តភាពថ្មីៗសម្រាប់ការអភិវឌ្ឍជាតិ ដែលបានឆ្លើយតបដ៏មានប្រសិទ្ធភាពទៅនឹងការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃស្ថានភាពសង្គម-សេដ្ឋកិច្ចក្នុងតំបន់ និងសកល ។ លើមូលដ្ឋាននេះ, រាជរដ្ឋាភិបាលបានប្រកាន់ខ្ជាប់នូវអភិក្រម "គិតគូរជាសកល និងអនុវត្តតាមបរិការណ៍ក្នុងប្រទេស" និង "រក្សាសមិទ្ធផលចាស់ បង្កើតសមិទ្ធផលថ្មី" ក៏ដូចជាបន្តពង្រីកការទូតសេដ្ឋកិច្ច និងពង្រឹងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ទន្ទឹមនឹងកែទម្រង់ស្ថាប័ន និងអភិបាលកិច្ចឱ្យកាន់តែមុតស្រួច និងមានប្រសិទ្ធភាព ក្នុងគោលដៅឈានទៅសម្រេចចក្ខុវិស័យកម្ពុជាជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ។ ដើម្បីសម្រេចគោលដៅប្រកបដោយមហិច្ឆតានេះ, រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្របញ្ចកោណ-

ដំណាក់កាលទី ១, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, គោលនយោបាយ និងយុទ្ធសាស្ត្រតាមវិស័យ ពិសេសបន្តអនុវត្តកម្មវិធីកែទម្រង់សំខាន់ៗ សំដៅអភិវឌ្ឍមូលធនមនុស្ស, ពង្រឹងរចនាសម្ព័ន្ធស្ថាប័ន, បង្កើនភាពប្រកួតប្រជែង និងពិពិធកម្មសេដ្ឋកិច្ច ក៏ដូចជាបង្កើនឱកាសការងារសម្រាប់ប្រជាជនគ្រប់រូប ។

ទោះបីកំពុងស្ថិតក្នុងឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាបទន្ទឹមនឹងការត្រៀមខ្លួនចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួចក៏ដោយ, រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលល្អប្រសើរក្នុងការកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការ និងពង្រឹងភាពជាដៃគូប្រកបដោយបរិយាប័ន្នជាមួយនឹងតួអង្គអភិវឌ្ឍន៍ ដើម្បីអភិវឌ្ឍប្រទេស ។ ជាក់ស្តែង នៅក្នុងឆ្នាំ២០២០-២០២៤, ដៃគូអភិវឌ្ឍន៍បានបើកផ្តល់ហិរញ្ញប្បទានប្រមាណ ២.០០០ លានដុល្លារអាមេរិក ជាមធ្យមក្នុងមួយឆ្នាំ ដែលនេះបង្ហាញពីការបន្តជំនឿទុកចិត្តពីដៃគូអភិវឌ្ឍន៍មកលើភាពដឹកនាំរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។ គួរកត់សម្គាល់ដែរថា, ការបើកផ្តល់ឥណទានសម្បទានបានកើនឡើងជាលំដាប់ ទន្ទឹមនឹងភាពនៅទ្រឹងនៃហិរញ្ញប្បទានឥតសំណងដែលការណ៍នេះបង្ហាញពីការប្រែប្រួលទម្រង់នៃការបើកផ្តល់ហិរញ្ញប្បទានជាបណ្តើរៗពីហិរញ្ញប្បទានឥតសំណងទៅឥណទានសម្បទាន ស្របពេលដែលកម្ពុជាកំពុងត្រៀមខ្លួនចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួចនាឆ្នាំ២០២៩ខាងមុខ ។

រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ខ្ពស់ និងតាមដានជាប្រចាំអំពីការវិវត្តនៃស្ថានភាពសកល ដូចជាជម្លោះភូមិសាស្ត្រនយោបាយ, សង្គ្រាមពាណិជ្ជកម្ម និងពន្ធគយ និងការបន្តដាក់សម្ពាធគោលនយោបាយគាំពារនិយម ក៏ដូចជាការរឹតត្បិតផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍មួយចំនួន ។ ក្នុងស្មារតីនេះ, រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូឆ្នាំ២០២៤-២០២៨ ដើម្បីបន្តពង្រឹងភាពជាដៃគូប្រកបដោយបរិយាប័ន្ន និងបង្កើនការកៀរគរហិរញ្ញប្បទាន ក៏ដូចជាលើកកម្ពស់ប្រសិទ្ធភាពនៅក្នុងការគ្រប់គ្រង និង

ការប្រើប្រាស់ធនធានទាំងនេះ សំដៅរួមចំណែកសម្រេចឱ្យបានគោលដៅអភិវឌ្ឍន៍ជាតិ ដូចមានចែងក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ ។

គោលបំណងចម្បងនៃរបាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូនេះ គឺដើម្បីវាយតម្លៃអំពីការវិវត្តនៃហិរញ្ញប្បទានសហប្រតិបត្តិការ និងត្រួតពិនិត្យវឌ្ឍនភាពនៃភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍ តាមរយៈការវិភាគផ្អែកលើសក្ខីកម្មជាក់ស្តែង ដើម្បីគាំទ្រដល់ការអនុវត្តអាទិភាពក្នុងការអភិវឌ្ឍជាតិដែលមានចែងក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា របាយការណ៍នេះអាចត្រូវបានប្រើប្រាស់សម្រាប់ធ្វើជាធាតុចូលសំខាន់ ក្នុងការរៀបចំគោលនយោបាយស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ហើយអាចប្រើប្រាស់ជាឯកសារយោងសម្រាប់កិច្ចសន្ទនាជាមួយនឹងភាគីពាក់ព័ន្ធ ដើម្បីពង្រឹងភាពជាដៃគូប្រកបដោយបរិយាប័ន្នផងដែរ ។

ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះកិច្ចសហការប្រកបដោយប្រសិទ្ធភាពខ្ពស់របស់ក្រសួងនិងស្ថាប័ន និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ក៏ដូចជាសហការីទាំងអស់នៅក្នុងគណៈកម្មាធិការសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដែលបានចូលរួម និងផ្តល់ការគាំទ្រដល់កិច្ចការដ៏សំខាន់នេះ ។

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០២៥

**ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស**
**អនុប្រធានទី ២ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា**

**ឈៀង យ៉ាណារ៉ា**

# មាតិកា

**ខ្លឹមសារសង្ខេបប្រតិបត្តិ** ..................... ............................ i
**ជំពូក ១ - សេចក្តីផ្តើម: បរិការណ៍នៃហិរញ្ញប្បទាន សហប្រតិបត្តិការ** .............................................. ១
**ជំពូក ២ - ការវិវត្តនៃការបើកផ្តល់ហិរញ្ញប្បទាន សហប្រតិបត្តិការ** ............................................. ៦
១. អនុបាតហិរញ្ញប្បទានធៀបនឹងផលិតផលក្នុងស្រុកសរុប និងហិរញ្ញប្បទានសម្រាប់ប្រជាជនម្នាក់ ................................ ៨
២. ការបើកផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ........................... ៩
៣. ការប្រែប្រួលសំខាន់ៗនៃការបើកផ្តល់ហិរញ្ញប្បទាន ..................... ១២
៤. ការបើកផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍តាមទម្រង់ ............ ១៤
៥. ការវិវត្តនៃការបើកផ្តល់ហិរញ្ញប្បទានតាមវិស័យ......................... ១៦
៦. ហិរញ្ញប្បទានសម្រាប់អន្តរវិស័យ .......................................... ១៨
៧. ការចូលរួមរបស់ដៃគូអភិវឌ្ឍន៍ក្នុងក្រុមការងារបច្ចេកទេសចម្រុះ ..... ១៨
៨. ការបើកផ្តល់ហិរញ្ញប្បទានតាមរាជធានី-ខេត្ត............................ ២២
៩. ការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍ជាតិ ...... ២៣
**ជំពូក ៣ - ការពង្រឹងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍** ............. ៣១
១. ការអង្កេតភាពជាដៃគូសកលលើកទី ៤ សម្រាប់ប្រសិទ្ធភាព នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍.......................................... ៣១
*ក. សូចនាករស្តីពីការប្រើប្រាស់ក្របខ័ណ្ឌលទ្ធផលជាតិ ដោយដៃគូអភិវឌ្ឍន៍* .............................................. ៣៣
*ខ. សូចនាករស្តីពីគុណភាពនៃផែនការអភិវឌ្ឍន៍ជាតិ និងក្របខ័ណ្ឌលទ្ធផលជាតិ* .......................................... ៣៣

*គ. សូចនាករស្តីពីបរិស្ថានអំណោយផលសម្រាប់សង្គមស៊ីវិល និងប្រសិទ្ធភាពក្នុងកិច្ចអភិវឌ្ឍន៍ ...................................... ៣៣*
*ឃ. សូចនាករស្តីពីការព្យាករណ៍ទំហំហិរញ្ញប្បទានសហប្រតិបត្តិការក្នុងរយៈពេលមធ្យម ................................ ៣៤*
*ង. សូចនាករស្តីពីគណនេយ្យភាពទ្វេទិសតាមរយៈការវាយតម្លៃប្រកបដោយបរិយាប័ន្ន .................... ៣៤*
*ច. សូចនាករស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយដៃគូអភិវឌ្ឍន៍........................... ៣៥*
២. វឌ្ឍនភាពក្នុងការអនុវត្តយន្តការភាពជាដៃគូ.............................. ៣៥
៣. លទ្ធផលនៃការពិនិត្យសមិទ្ធកម្មរបស់ក្រុមការងារបច្ចេកទេសចម្រុះ ៣៦
**ជំពូក ៤ - ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រដល់ការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា**.................................... ៣៨
**ជំពូក ៥ - សេចក្តីសន្និដ្ឋាន**........................................................ ៤៣

# បញ្ជីតារាង

តារាងទី ២.១: ការបើកផ្ដល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍................ ១១
តារាងទី ២.២: ការបើកផ្ដល់ហិរញ្ញប្បទានតាមទម្រង់ ........................... ១៥
តារាងទី ២.៣: ការបើកផ្ដល់ហិរញ្ញប្បទានតាមវិស័យ............................ ១៧
តារាងទី ២.៤: ការបើកផ្ដល់ហិរញ្ញប្បទានសម្រាប់អន្តរវិស័យ ................ ១៨
តារាងទី ២.៥: ការបើកផ្ដល់ហិរញ្ញប្បទានតាមក្រុមការងារបច្ចេកទេសចម្រុះ១៩
តារាងទី ២.៦: ដៃគូអភិវឌ្ឍន៍សំខាន់ៗក្នុងក្រុមការងារបច្ចេកទេសចម្រុះ...២២
តារាងទី ២.៧: ការបើកផ្ដល់ហិរញ្ញប្បទានតាមរាជធានី-ខេត្ត.................២៣
តារាងទី ២.៨: ធនធានរបស់អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យ..........២៥
តារាងទី ២.៩: ធនធានរបស់អង្គការមិនមែនរដ្ឋាភិបាលសំខាន់ៗ............២៨
តារាងទី ៣.១: ក្របខ័ណ្ឌលទ្ធផលស្ដីពីស័ក្ដិសិទ្ធភាពក្នុងកិច្ចអភិវឌ្ឍន៍......៣២
តារាងទី ៤.១: ការបើកផ្ដល់ហិរញ្ញប្បទានតាមគោលដៅអភិវឌ្ឍន៍ ប្រកបដោយចីរភាពកម្ពុជា ........................................ ៣៩
តារាងទី ៤.២: ការបើកផ្ដល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍សំខាន់ៗ តាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ២០២៣...៤២

# បញ្ជីគំនូរ


គំនូរទី ២.១: ការបើកផ្ដល់ហិរញ្ញប្បទានសហប្រតិបត្តិការ......................៦
គំនូរទី ២.២: អនុបាតហិរញ្ញប្បទានធៀបនឹងផលិតផលក្នុងស្រុកសរុប....៨
គំនូរទី ២.៣: ការប្រៀបធៀបហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍................១២
គំនូរទី ២.៤: ការបើកផ្ដល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍តាមទម្រង់....១៣
គំនូរទី ២.៥: ធនធានសរុបរបស់អង្គការមិនមែនរដ្ឋាភិបាល ..................២៤
គំនូរទី ២.៦: ការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យ ឆ្នាំ២០២៣-២០២៥..................................................២៦
គំនូរទី ២.៧: ភាគរយនៃធនធានរបស់អង្គការមិនមែនរដ្ឋាភិបាល ឆ្នាំ២០២៣-២០២៥..................................................២៧

# បញ្ជីឧបសម្ព័ន្ធ


ឧបសម្ព័ន្ធទី ១: ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ
តាមដៃគូអភិវឌ្ឍន៍ និងតាមវិស័យ ឆ្នាំ២០២២................. ៤៧

ឧបសម្ព័ន្ធទី ២: ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ
តាមដៃគូអភិវឌ្ឍន៍ និងតាមវិស័យ ឆ្នាំ២០២៣ ................ ៥០

ឧបសម្ព័ន្ធទី ៣: ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ
តាមដៃគូអភិវឌ្ឍន៍ និងតាមវិស័យ ឆ្នាំ២០២៤................. ៥៣

ឧបសម្ព័ន្ធទី ៤: ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ
តាមដៃគូអភិវឌ្ឍន៍ និងតាមវិស័យ ឆ្នាំ២០២៥................. ៥៦

ឧបសម្ព័ន្ធទី ៥: ការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍
ឆ្នាំ២០១៦-២០២៥................................................. ៥៩

ឧបសម្ព័ន្ធទី ៦: ការបើកផ្តល់ហិរញ្ញប្បទានតាមវិស័យ
ឆ្នាំ២០១៦-២០២៥................................................. ៦១

ឧបសម្ព័ន្ធទី ៧: ការបើកផ្តល់ហិរញ្ញប្បទានតាមរាជធានី-ខេត្ត
ឆ្នាំ២០២២-២០២៥ ................................................ ៦៣

# ខ្លឹមសារសង្ខេបប្រតិបត្តិ

ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយ និងការអនុវត្ត "នយោបាយឈ្នះ-ឈ្នះ" ប្រកបដោយភាពប្រាកដនិយមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**, កម្ពុជារក្សាបាននូវសន្តិភាព, ស្ថិរភាពនយោបាយ, សណ្តាប់ធ្នាប់សង្គម និងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច។ ជាមួយគ្នានេះ, រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលដ៏ត្រចះត្រចង់នៅក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ដោយបានជំរុញកំណើនសេដ្ឋកិច្ចជាតិឱ្យមានសន្ទុះកើនឡើងបន្តបន្ទាប់ក្នុងរយៈពេលជាង ២ ទសវត្សរ៍ និងបានលើកកម្ពស់ជីវភាពរបស់ប្រជាជន តាមរយៈការអនុវត្តក្របខ័ណ្ឌគោលនយោបាយសំខាន់ៗ និងវិធានការមុតស្រួចនានា ដែលបានធ្វើឱ្យកម្ពុជាផ្លាស់ប្តូរមុខមាត់ថ្មី ពិសេសការសម្រេចបានឋានៈជាប្រទេសមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៦ ហើយបានត្រៀមខ្លួនចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួចនាចុងឆ្នាំ២០២៩។

## ការវិវត្តនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍

ទោះបីបរិបទសេដ្ឋកិច្ច និងស្ថានភាពភូមិសាស្ត្រនយោបាយក្នុងតំបន់ និងសកល អាចប៉ះពាល់ជាអវិជ្ជមានដល់លទ្ធភាពធនធានរបស់ដៃគូអភិវឌ្ឍន៍, ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការមាន ២.១០០ លានដុល្លារអាមេរិក (តទៅហៅកាត់ថាលានដុល្លារ) ជាមធ្យមក្នុងមួយឆ្នាំ ក្នុងចន្លោះឆ្នាំ ២០២១-២០២៥ ។ ក្នុងឆ្នាំ២០២៣ ហិរញ្ញប្បទានបានកើនដល់ជាង ២.១០០ លានដុល្លារ ធៀបឆ្នាំ២០២១ ហើយបន្តកើនដល់ជិត ២.២០០ លានដុល្លារ ក្នុងឆ្នាំ២០២៤។ ទំហំនេះអាចនឹងថយចុះបន្តិចមកត្រឹមប្រមាណ ២.១០០ លានដុល្លារ ក្នុងឆ្នាំ២០២៥ ។ ការបើកផ្តល់ហិរញ្ញប្បទានឥតសំណងក្នុងឆ្នាំ២០២៤ បានរក្សាទំហំថេរក្នុងរង្វង់ ៩០០ លានដុល្លារ ប្រមាណ ៤០% នៃហិរញ្ញប្បទានសរុប ។

ឥណទានសម្បទានបានកើនដល់ជាង ១.៣០០ លានដុល្លារ ប្រមាណ ៦០% នៃហិរញ្ញប្បទានសរុប ក្នុងឆ្នាំ២០២៤ ។

**ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ (លានដុល្លារ)**




ក្នុងឆ្នាំ២០២១-២០២៥, អនុបាតហិរញ្ញប្បទានធៀបនឹងផលិតផលក្នុងស្រុកសរុប បានរក្សាទំហំថេរក្នុងរង្វង់ ៥% ។ ក្នុងឆ្នាំ២០២១, អនុបាតនេះមានប្រមាណ ៥% ហើយបានថយចុះមកត្រឹម ៤% ក្នុងឆ្នាំ២០២៥ ប៉ុន្តែរំពឹងថាអាចស្ថិតក្នុងកម្រិតនេះ ឬទាបជាងកម្រិតនេះសម្រាប់រយៈពេលមធ្យមទៅមុខ ។ ក្នុងឆ្នាំ២០២៣-២០២៥, ហិរញ្ញប្បទានសម្រាប់ប្រជាជនម្នាក់រក្សាបានទំហំជាមធ្យមក្នុងរង្វង់ ១៣០ ដុល្លារ ។

ហិរញ្ញប្បទានដែលបើកផ្តល់ដោយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ (ធនាគារអភិវឌ្ឍន៍អាស៊ី, ធនាគារពិភពលោក និងអង្គការមូលនិធិអន្តរជាតិដទៃទៀត)

មានទំហំជាង ៣០០ លានដុល្លារ ក្នុងឆ្នាំ២០២១ និងបានកើនដល់ជិត ៦០០ លានដុល្លារក្នុងមួយឆ្នាំ ក្នុងចន្លោះឆ្នាំ២០២២-២០២៤ ហើយរំពឹងថាអាចនឹងកើនដល់ ៨០០ លានដុល្លារ ក្នុងឆ្នាំ២០២៥ ។ ទន្ទឹមនឹងនេះ, ដៃគូអភិវឌ្ឍន៍ទ្វេភាគីបានបើកផ្តល់ហិរញ្ញប្បទានក្នុងរង្វង់ ១.០០០ លានដុល្លារក្នុងមួយឆ្នាំ ក្នុងចន្លោះឆ្នាំ២០២១-២០២៥ ហើយអាចធ្លាក់ចុះមកត្រឹមជិត ៧៥០ លានដុល្លារក្នុងឆ្នាំ២០២៥ ដោយសារដៃគូអភិវឌ្ឍន៍មួយចំនួនមិនទាន់ព្យាករណ៍ការបើកផ្តល់ហិរញ្ញប្បទានរបស់ខ្លួនបានពេញលេញ ។

**ការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ (លានដុល្លារ)**

| ដៃគូអភិវឌ្ឍន៍ | 2016-2020 | 2021 | 2022 | 2023 | 2024 | 2025 ប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **ភ្នាក់ងារអង្គការសហប្រជាជាតិ** | | | | | | |
| ធនធានសរុប | 440.7 | 109.7 | 126.5 | 80.4 | 123.7 | 160.2 |
| ធនធានផ្ទាល់ | 335.9 | 89.3 | 108.3 | 80.4 | 105.3 | 160.2 |
| **ដៃគូពហុភាគី** | | | | | | |
| ធនាគារពិភពលោក | 236.5 | 73 | 312 | 158.5 | 177.6 | 228.5 |
| ធនាគារអភិវឌ្ឍន៍អាស៊ី | 1,070.3 | 204 | 240.3 | 394.5 | 361.7 | 455.7 |
| GAVI Alliance | 64 | 9.1 | - | - | - | - |
| IAEA | | - | 0.3 | - | - | - |
| មូលនិធិសកល | 161.7 | 29.6 | 39.2 | 44.1 | 34.5 | 32.4 |
| **សរុប** | **1,532.5** | **315.7** | **591.8** | **597.1** | **573.8** | **716.7** |
| **សហភាពអឺរ៉ុប** | | | | | | |
| គណៈកម្មការអឺរ៉ុប | 351.1 | 76.2 | 81.6 | 47.9 | 47.7 | 54.4 |
| សាធារណរដ្ឋឆែក | 7.7 | 2.5 | 2.9 | 2.5 | 2.2 | 1.8 |
| បារាំង | 484.6 | 117.8 | 58 | 49.7 | 169.8 | 79.2 |
| អាល្លឺម៉ង់ | 175.2 | 31.5 | 59.6 | 41.4 | 39.5 | 69.8 |
| អៀរឡង់ | 4 | 1.6 | 1.5 | 1.6 | 2.7 | - |
| ស៊ុយអែត | 137.9 | 22.7 | 17.2 | 14.9 | 11.7 | 0.5 |
| ចក្រភពអង់គ្លេស | 7 | 3.4 | 2 | 1.2 | 0.4 | 0.4 |
| **សរុប** | **1,167.6** | **255.7** | **222.6** | **159.2** | **273.9** | **206.2** |

| ដៃគូអភិវឌ្ឍន៍ | 2016-2020 | 2021 | 2022 | 2023 | 2024 | 2025 ប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **ដៃគូទ្វេភាគី** | | | | | | |
| អូស្ត្រាលី | 234.5 | 64.8 | 43.4 | 48.7 | 46.2 | 43.9 |
| កាណាដា | 15.4 | 3.5 | 3.2 | 2.6 | 2.2 | 1.6 |
| សាធារណរដ្ឋប្រជាមានិតចិន | 2,073.4 | 420.9 | 235.9 | 386.1 | 268.3 | 286 |
| ជប៉ុន | 1,150.8 | 227.7 | 561.1 | 286.4 | 250.7 | 139 |
| នូវែលសេឡង់ | 27.1 | 7.8 | 3.8 | 10.9 | 7.5 | 5.5 |
| សាធារណរដ្ឋកូរ៉េ | 327.6 | 122.2 | 128.8 | 108.4 | 228.7 | 244.6 |
| ស្វីស | 73.3 | 16.8 | 13.8 | 17.9 | 18.1 | 14.7 |
| ថៃឡង់ | | 7.3 | 3.6 | - | - | - |
| សហរដ្ឋអាមេរិក | 452.7 | 105.3 | 116.6 | 133.6 | 118.6 | - |
| **សរុប** | **4,354.9** | **976.3** | **1110** | **994.6** | **940.3** | **735.4** |
| **អង្គការមិនមែនរដ្ឋាភិបាល (ធនធានផ្ទាល់)** | **1,313.7** | **258.9** | **260.7** | **275.6** | **293.5** | **277.5** |
| **សរុបរួម** | **8,704.6** | **1,896.1** | **2,293.4** | **2,106.9** | **2,186.9** | **2,096.0** |

ការបើកផ្តល់ហិរញ្ញប្បទានបានតម្រឹមល្អប្រសើរជាមួយនឹងអាទិភាពរបស់រាជរដ្ឋាភិបាល ដូចមានចែងក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១ ។ វិស័យហេដ្ឋារចនាសម្ព័ន្ធទទួលបានហិរញ្ញប្បទានច្រើនជាងគេប្រមាណ ៧១៤ លានដុល្លារ ក្នុងឆ្នាំ២០២៤ ។ រីឯវិស័យសេដ្ឋកិច្ច និងសង្គមកិច្ចទទួលបានធនធានជិត ៦០០ លានដុល្លារ និង ៥០០ លានដុល្លារ ក្នុងរយៈពេលដូចគ្នា ។ ហិរញ្ញប្បទានមួយផ្នែកធំត្រូវបានប្រើប្រាស់ សម្រាប់អភិវឌ្ឍវិស័យសុខាភិបាល អប់រំ កសិកម្ម ថាមពល និងដឹកជញ្ជូន ។ និន្នាការនេះបានបង្ហាញអំពីអាទិភាពរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។

ការបើកផ្តល់ហិរញ្ញប្បទានតាមវិស័យ ឆ្នាំ២០២៤ (លានដុល្លារ)




## ការពង្រឹងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍

រាជរដ្ឋាភិបាលបានប្តេជ្ញាបន្តអនុវត្តគោលការណ៍ស្តីពីស័ក្តិសិទ្ធភាពនៃកិច្ចអភិវឌ្ឍន៍ ។ បន្ទាប់ពីទទួលបានជោគជ័យក្នុងការចូលរួមការអង្កេតភាពជាដៃគូសកល ៣ លើករួចមក, ក្នុងឆ្នាំ២០២៤នេះ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាក្នុងនាមរាជរដ្ឋាភិបាល ដោយសហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល បានចូលរួមក្នុងការធ្វើអង្កេតលើកទី៤ សម្រាប់ប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។ លទ្ធផលបានបង្ហាញថា កម្ពុជាសម្រេចបានវឌ្ឍនភាពល្អស្ទើរគ្រប់សូចនាករទាំងអស់ ធៀបនឹងលទ្ធផលនៃការអង្កេតលើកទី៣ក្នុងឆ្នាំ២០១៨ ខណៈដែលមានសូចនាករតិចតួចទាមទារការពង្រឹងបន្ថែមទៀត ដូចជាការប្រើប្រាស់ប្រព័ន្ធជាតិដោយដៃគូអភិវឌ្ឍន៍ ។ លើសពីនេះ, ក្នុងក្របខ័ណ្ឌនៃការអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការ

អភិវឌ្ឍន៍ និងភាពជាដៃគូ, ការអនុវត្តយន្តការភាពជាដៃគូប្រកបដោយបរិយាប័ន្ន ក៏សម្រេចបានវឌ្ឍនភាពគួរកត់សម្គាល់។ ជាក់ស្តែង ក្នុងឆ្នាំ២០២៤, កិច្ចពិគ្រោះយោបល់ភាពជាដៃគូសំខាន់ៗជាច្រើនត្រូវបានរៀបចំឡើង រួមមានកិច្ចពិគ្រោះយោបល់កម្រិតខ្ពស់រវាង **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** ជាមួយប្រព័ន្ធអង្គការសហប្រជាជាតិ, កិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីអភិវឌ្ឍន៍ប្រចាំប្រទេសរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំកម្ពុជា និងមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជនប្រចាំកម្ពុជា, កិច្ចពិគ្រោះយោបល់ជាមួយសាធារណរដ្ឋកូរ៉េ, កិច្ចពិគ្រោះយោបល់ជាមួយសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងកិច្ចពិគ្រោះយោបល់ជាមួយសហភាពអឺរ៉ុបជាដើម ។ លើសពីនេះ, ក៏បានរៀបចំត្រួតពិនិត្យសមិទ្ធកម្មរបស់ក្រុមការងារបច្ចេកទេសចម្រុះ ។ លទ្ធផលបានបង្ហាញថា យន្តការនេះបានដំណើរការយ៉ាងល្អប្រសើរ ដោយក្រុមការងារបានដំណើរការផ្អែកទៅតាមលក្ខខណ្ឌយោងច្បាស់លាស់ ។ ទន្ទឹមនឹងនេះ, ក្រុមការងារភាគច្រើនបានរាយការណ៍ពីវឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព, ការរៀបចំកិច្ចប្រជុំ និងការចូលរួមយ៉ាងសកម្ម និងប្រកបដោយបរិយាប័ន្នពីតួអង្គពាក់ព័ន្ធ ។

## ការបើកផ្តល់ហិរញ្ញប្បទានសម្រាប់គាំទ្រដល់ការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក) ត្រូវបានធ្វើសមាហរណកម្មទៅក្នុងក្របខ័ណ្ឌគោលនយោបាយជាតិសំខាន់ៗ ដើម្បីធានាសង្គតិភាពរវាងឯកសារយុទ្ធសាស្ត្រ ។ រាជរដ្ឋាភិបាលបាន និងបន្តកៀរគរហិរញ្ញប្បទានពីគ្រប់តួអង្គអភិវឌ្ឍន៍ ដើម្បីគាំទ្រដល់ការអនុវត្តគោលដៅទាំង ១៨ នៃ គ.អ.ច.ក ។ គោលដៅទី៣ ស្តីពី "សុខភាពល្អ និងសុខុមាលភាព" និងគោលដៅទី៩ ស្តីពី "ឧស្សាហកម្ម, នវានុវត្តន៍ និង ហេដ្ឋារចនាសម្ព័ន្ធ" ទទួលបានការគាំទ្រ

ច្រើនជាងគេ ។ ក្នុងឆ្នាំ ២០២២-២០២៥, គោលដៅទី៩ ទទួលបានការគាំទ្រច្រើនជាមធ្យម ២៨% នៃហិរញ្ញប្បទានសរុបដែលគាំទ្រ គ.អ.ច.ក ខណៈដែលគោលដៅទី៣ទទួលបានការគាំទ្រច្រើនលំដាប់ទី២ ស្មើនឹង ១៤%។ នេះបង្ហាញពីការតម្រឹមហិរញ្ញប្បទានជាមួយនឹងអាទិភាពអភិវឌ្ឍន៍ជាតិ ដូចជាការអភិវឌ្ឍធនធានមនុស្ស និងការកសាងហេដ្ឋារចនាសម្ព័ន្ធជាដើម ។

សរុបមក, ហិរញ្ញប្បទានសហប្រតិបត្តិការបានបន្តតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ហើយជាកាតាលីករសម្រាប់កៀរគរធនធានបន្ថែមសម្រាប់បំពេញឱ្យធនធាននៅក្នុងស្រុក សំដៅជំរុញកិច្ចអភិវឌ្ឍន៍ជាតិឈានទៅសម្រេចចក្ខុវិស័យឆ្នាំ២០៥០ ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានប្តេជ្ញាយ៉ាងមុតមាំក្នុងការបន្តពង្រឹងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូប្រកបដោយបរិយាប័ន្នជាមួយតួអង្គអភិវឌ្ឍន៍ទាំងអស់ ដើម្បីកៀរគរ សម្របសម្រួល និងគ្រប់គ្រងធនធានទាំងនេះប្រកបដោយប្រសិទ្ធភាព ។

# ជំពូក ១

## សេចក្តីផ្តើម : បរិការណ៍នៃហិរញ្ញប្បទានសហប្រតិបត្តិការ

ក្នុងបរិការណ៍នៃសុខសន្តិភាព, ឯកភាពជាតិ, ស្ថិរភាពនយោបាយ, អធិបតេយ្យភាព និងបូរណភាពទឹកដី, សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គម ដែលជាសមិទ្ធផលមិនអាចកាត់ថ្លៃបាននៃ "នយោបាយឈ្នះ-ឈ្នះ" របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី និងបច្ចុប្បន្នជាប្រធានព្រឹទ្ធសភា, រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តប្រកបដោយជោគជ័យនូវកម្មវិធីនយោបាយរបស់ខ្លួន ដោយរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងសម្រេចបានបរិវត្តកម្មសំខាន់ៗជាច្រើនគួរជាទីមោទនៈ ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ។ សមិទ្ធផលដ៏ត្រចះត្រចង់ និងជាបន្តបន្ទាប់លើគ្រប់វិស័យទាំងនយោបាយ, សង្គម និងសេដ្ឋកិច្ច ក្នុងរយៈពេលជាង២ទសវត្សរ៍កន្លងមក បាននាំឱ្យកម្ពុជាសម្រេចបាននូវការផ្លាស់ប្តូរមុខមាត់ថ្មី ពិសេសការកាត់បន្ថយភាពក្រីក្រគួរឱ្យកត់សម្គាល់ និងការសម្រេចបានឋានៈប្រទេសមានចំណូលមធ្យមកម្រិតទាប ។

លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា ក្រោមការដឹកនាំប្រកបដោយថាមភាព និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានបន្តពូនជ្រុំ និងបង្កើតសមិទ្ធផលថ្មីៗបន្ថែម ដោយសម្លឹងឆ្ពោះទៅមុខក្នុងភាពជឿជាក់ និងឆន្ទៈមោះមុត ក្នុងការបន្តកិច្ចអភិវឌ្ឍន៍ និងចាប់យកកាលានុវត្តភាព នៅក្នុងបរិការណ៍នៃការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃស្ថានភាពសង្គម-សេដ្ឋកិច្ចតំបន់ និងសកល ។ ក្នុងន័យនេះ, រាជរដ្ឋាភិបាលបានដាក់ចេញឱ្យអនុវត្តនូវ "យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១" ដោយប្រកាន់ខ្ជាប់អភិក្រម "ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់" និងអភិក្រម "ជវភាពនៃប្រព័ន្ធតួអង្គតែមួយ"

ដើម្បីបន្តពន្លឿនការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងលើកកម្ពស់វិបុលភាព និងកិត្យានុភាពជាតិ ។

ក្នុងរយៈពេលជិត២ឆ្នាំកន្លងមក, រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលជាច្រើនក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ពិសេសក្នុងការអនុវត្តកម្មវិធីគោលនយោបាយអាទិភាពទាំង៦ និងវិធានការគន្លឹះទាំង៥ សំដៅលើកកម្ពស់ជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាជន។ ការរក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, ការគ្រប់គ្រងបានអតិផរណា និងការសម្រេចកំណើនក្នុងរង្វង់ប្រមាណ ៦% ក្នុងឆ្នាំ២០២៤ និងការប៉ាន់ស្មានកំណើនប្រមាណ ៦,៣% ក្នុងឆ្នាំ២០២៥ នឹងជួយឱ្យកម្ពុជារក្សាបានជំហរដ៏រឹងមាំលើគន្លងនៃការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួចនៅឆ្នាំ២០២៩ ដើម្បីឈានទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ។

ទោះជាយ៉ាងនេះក្តី សេដ្ឋកិច្ចកម្ពុជាដែលទើបបានស្តារឡើងវិញបន្ទាប់ពីវិបត្តិកូវីដ-១៩ ត្រូវបានបន្ទច់បង្អាក់ដោយសារការវិវត្តស្មុគស្មាញ និងភាពមិនប្រាកដប្រជានៃសភាពការណ៍តំបន់និងសកលលោក, ការប្រកួតប្រជែងភូមិសាស្ត្រនយោបាយ, សង្គ្រាមសេដ្ឋកិច្ច និងពាណិជ្ជកម្មអន្តរជាតិ, អតិផរណា, ការកើនឡើងយ៉ាងឆាប់រហ័សនៃសេដ្ឋកិច្ចឌីជីថល, ការប្រណាំងប្រជែងផ្នែកបច្ចេកវិទ្យាកាន់តែស្រួចស្រាល់ និងការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ ក៏ដូចជាពីឥទ្ធិពលនៃជម្លោះ និងសង្គ្រាមតាមតំបន់មួយចំនួន ។ ជារួម សេដ្ឋកិច្ចសកលបន្តមានហានិភ័យ និងមានភាពមិនប្រាកដប្រជាខ្ពស់ ដែលតម្រូវឱ្យមានកិច្ចសហការដោះស្រាយរួមគ្នានូវបញ្ហាប្រឈមទាំងនេះ។ ក្នុងខណៈដែលសេដ្ឋកិច្ចបើកចំហ និងសកលភាវូបនីយកម្មរបស់កម្ពុជាអាចទទួលរងផលអវិជ្ជមានពីកត្តាខាងក្រៅទាំងនេះ ក្នុងរយៈពេលខ្លី និងមធ្យមខាងមុខ, រាជរដ្ឋាភិបាលបានប្រកាន់យកនូវអភិក្រមបុរេសកម្មក្នុងការគ្រប់គ្រង ដើម្បីបត់បែនឱ្យទាន់សភាពការណ៍

នៃការវិវត្តឆាប់រហ័សនៃនិម្មាបនកម្មសកល ក្នុងគោលដៅប្រែក្លាយបញ្ហាប្រឈមទាំងនេះឱ្យទៅជាកាលានុវត្តភាពសម្រាប់លើកកម្ពស់ប្រសិទ្ធភាព និងភាពប្រកួតប្រជែងសេដ្ឋកិច្ច, កែលម្អបរិស្ថានវិនិយោគដើម្បីកៀរគរការវិនិយោគ និងធុរកិច្ចបន្ថែមកាន់តែច្រើនមកកម្ពុជា។ លើសពីនេះ កម្ពុជាកំពុងសម្របខ្លួន និងចាប់យកអត្ថប្រយោជន៍ពីការរីកចម្រើននៃបច្ចេកវិទ្យា និងឌីជីថលូបនីយកម្មក្នុងបរិការណ៍នៃបដិវត្តន៍ឧស្សាហកម្មទី៤ ឱ្យបានជាអតិបរមាសម្រាប់បង្កើនផលិតភាព និងប្រសិទ្ធភាពសេដ្ឋកិច្ច ក៏ដូចជាលើកកម្ពស់ពិពិធកម្មសេដ្ឋកិច្ចនៅកម្ពុជា។

ក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ, រាជរដ្ឋាភិបាលសម្រេចបានជោគជ័យក្នុងការពង្រឹងទំនាក់ទំនងជាមួយនឹងបណ្តាប្រទេស និងស្ថាប័នក្នុងតំបន់ និងសកលលោក ដោយបានប្រកាន់ខ្ជាប់នូវនយោបាយការបរទេសឯករាជ្យផ្អែកលើច្បាប់, បានអនុវត្តយ៉ាងសកម្មនូវការទូតសេដ្ឋកិច្ច និងបានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវអភិក្រម "រក្សាចាស់, ពង្រីកថ្មី"។ ប៉ុន្តែ ការវិវត្តស្ថានការណ៍អន្តរជាតិ ក៏ដូចជាបញ្ហាប្រឈមដូចបានរៀបរាប់ខាងលើ បានជំរុញឱ្យដៃគូអភិវឌ្ឍន៍មួយចំនួនអនុវត្តគោលនយោបាយរឹតត្បិតខាងសេដ្ឋកិច្ចនិងពាណិជ្ជកម្ម ទន្ទឹមនឹងការអនុវត្តគោលនយោបាយបង្វែរហិរញ្ញប្បទានទាំងនេះដោយថាហេតុទៅឱ្យតំបន់ ឬប្រទេសដែលមានតម្រូវការខ្ពស់ជាង ឬសម្រាប់បម្រើដល់គោលដៅមនុស្សធម៌ ក្នុងពេលដែលកម្ពុជាមានតម្រូវការធនធានវិនិយោគយ៉ាងគំហុក សម្រាប់បន្តអភិវឌ្ឍដើម្បីចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួចនាឆ្នាំ២០២៩ និងឈានទៅសម្រេចឋានៈប្រទេសមានចំណូលខ្ពស់នាឆ្នាំ២០៥០ ។

ក្នុងបរិការណ៍នេះ, រាជរដ្ឋាភិបាលបានទទួលស្គាល់អំពីភាពចាំបាច់ក្នុងការបន្តពង្រឹងភាពជាដៃគូប្រកបដោយបរិយាប័ន្នជាមួយបណ្តាស្ថាប័ន និងប្រទេសជាដៃគូ ក៏ដូចជាតួអង្គអភិវឌ្ឍន៍ទាំងអស់ ។ ទន្ទឹមនឹងនេះ, ការបន្តលើកកម្ពស់ស័ក្តិសិទ្ធភាពក្នុងការប្រើប្រាស់ហិរញ្ញប្បទានសហប្រតិបត្តិការ ក៏ដូចជាតួនាទី

កាន់តែសំខាន់ជាកាតាលីករសម្រាប់កៀរគរប្រភពហិរញ្ញប្បទានដទៃទៀតដើម្បីបំពេញបន្ថែមឱ្យធនធានក្នុងស្រុកសម្រាប់អភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា បានក្លាយជារបៀបវារៈកាន់តែសំខាន់ឡើងក្នុងបរិការណ៍ថ្មី ។ លើមូលដ្ឋាននេះ, រាជរដ្ឋាភិបាលនីតិកាលទី៧នៃរដ្ឋសភា បានដាក់ឱ្យអនុវត្តនូវ "យុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០២៤-២០២៨" សំដៅលើកកម្ពស់ភាពជាម្ចាស់របស់រាជរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍, ជំរុញស័ក្តិសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងពង្រឹងភាពជាដៃគូប្រកបដោយបរិយាប័ន្នដើម្បីរួមចំណែកការសម្រេចគោលដៅអភិវឌ្ឍន៍ជាតិ ដូចមានកំណត់នៅក្នុង "យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១" ។

"យុទ្ធសាស្ត្រស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០២៤-២០២៨" បានកំណត់គោលដៅ, យន្តការភាពជាដៃគូ និងឧបករណ៍សម្រាប់អនុវត្ត និងក្របខ័ណ្ឌលទ្ធផលដែលបានកំណត់សូចនាករមួយចំនួនសម្រាប់តាមដានវាយតម្លៃ ។ គណៈកម្មាធិការសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (គ.ស.អ.ក/ក.អ.ក) បានរៀបចំរបាយការណ៍ស្ដីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០២៥ ដើម្បីឆ្លុះបញ្ចាំង និងវិភាគស៊ីជម្រៅលើការវិវត្តនៃហិរញ្ញប្បទានសហប្រតិបត្តិការ ដោយផ្អែកលើសក្ខីកម្មជាក់ស្ដែង ក៏ដូចជារំលេចអំពីវឌ្ឍនភាព និងបញ្ហាប្រឈមក្នុងការអនុវត្តយន្តការភាពជាដៃគូ និងឧបករណ៍ និងក្របខ័ណ្ឌលទ្ធផលដែលសម្រេចបានក្នុងរយៈពេល១ឆ្នាំ បន្ទាប់ពីយុទ្ធសាស្ត្រនេះត្រូវបានប្រកាសដាក់ឱ្យអនុវត្តកាលពីថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០២៣កន្លងមក ។ ក្នុងន័យនេះ, របាយការណ៍នេះអាចប្រើប្រាស់សម្រាប់ជាធាតុចូលក្នុងការរៀបចំយុទ្ធសាស្ត្រ និងគោលនយោបាយអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចកម្ពុជា ក៏ដូចជាសម្រាប់តម្រង់ទិសការពិភាក្សាសំដៅ

ពង្រឹងភាពជាដៃគូប្រកប ដោយបរិយាប័ន្ន និងលើកកម្ពស់ស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការ ។

របាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូនេះ បែកចេញជា ៥ ជំពូក រួមមាន៖ ១- សេចក្តីផ្តើម, ២- វឌ្ឍនភាពនៃការកៀរគរហិរញ្ញប្បទានសហប្រតិបត្តិការអភិវឌ្ឍន៍, ៣- វឌ្ឍនភាពនៃការពង្រឹងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍, ៤- ការគាំទ្រហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា និង ៥- សេចក្តីសន្និដ្ឋាន ។

# ជំពូក ២

## ការវិវត្តនៃការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ

រាជរដ្ឋាភិបាលសម្រេចបានវឌ្ឍនភាពសំខាន់ៗជាច្រើននៅក្នុងការកៀរគរ សម្របសម្រួល និងគ្រប់គ្រងកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ប្រកបដោយស័ក្តិសិទ្ធភាពនិងបរិយាប័ន្ន ដែលបានរួមចំណែកគាំទ្រដល់ការអនុវត្តយុទ្ធសាស្រ្តបញ្ចកោណ-ដំណាក់កាលទី ១។ ជំពូកនេះនឹងធ្វើការវិភាគអំពីការវិវត្តនៃការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ ឆ្នាំ២០២៣-២០២៤ និងការប៉ាន់ស្មានឆ្នាំ២០២៥ ដោយប្រើប្រាស់ទិន្នន័យពីប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ គិតត្រឹមខែមីនា ឆ្នាំ២០២៥ ។ ទន្ទឹមនឹងនេះ, ការវិភាគនឹងបង្ហាញពីការប្រែប្រួលសំខាន់ៗនៃការបើកផ្តល់ហិរញ្ញប្បទាន ដែលរួមមានទម្រង់នៃការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍, ការបើកផ្តល់តាមវិស័យ និងអនុវិស័យ ក៏ដូចជាការបើកផ្តល់តាមរាជធានី-ខេត្ត និងតួនាទីរបស់ហិរញ្ញប្បទានក្នុងការគាំទ្រគោលនយោបាយ និងកិច្ចអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចកម្ពុជា ។

**គំនូរទី ២.១ : ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការ (លានដុល្លារ)**



ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការសរុបបានកើនពីប្រមាណ ២.០០០ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៩ (តទៅហៅកាត់ថាលានដុល្លារ) ដល់ជាង ២.៤០០ លានដុល្លារ ក្នុងឆ្នាំ២០២០ ហើយបន្តរក្សា ២.១០០ លានដុល្លារ ជាមធ្យមក្នុងមួយឆ្នាំ ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយ ២០២១-២០២៥ ។ ជាក់ស្តែង, ការបើកផ្តល់មានទំហំជិត ១.៩០០ លានដុល្លារ ក្នុងឆ្នាំ២០២១ និងបានកើនដល់ជាង ២.០០០ លានដុល្លារ ក្នុងឆ្នាំ២០២២, ជាង ២.១០០ លានដុល្លារ ក្នុងឆ្នាំ២០២៣ និងជិត ២.២០០ លានដុល្លារ ក្នុងឆ្នាំ២០២៤ ។ ដោយឡែក ក្នុងឆ្នាំ២០២៥, ការបើកផ្តល់ហិរញ្ញប្បទានត្រូវបានប៉ាន់ស្មានថាមានទំហំប្រមាណ ២.១០០ លានដុល្លារ។ តួលេខនេះមិនរាប់បញ្ចូលកិច្ចសហប្រតិបត្តិការរបស់សហរដ្ឋអាមេរិកឡើយ ដែលមានធនធានជិត ១០០ លានដុល្លារ ជាមធ្យមក្នុងមួយឆ្នាំ បន្ទាប់ពីបានប្រកាសផ្អាកការផ្តល់ជំនួយកាលពីដើមឆ្នាំ២០២៥នេះ ។ សម្រាប់ឆ្នាំ២០២៦, ការបើកផ្តល់ហិរញ្ញប្បទានអាចមានទំហំច្រើនជាងនេះ ដោយសារដៃគូអភិវឌ្ឍន៍មួយចំនួននៅមិនទាន់ផ្តល់ព័ត៌មានពេញលេញពីផែនការបើកផ្តល់ហិរញ្ញប្បទានរបស់ខ្លួន ។

ទោះបីជាបរិបទសេដ្ឋកិច្ច និងស្ថានភាពភូមិសាស្ត្រនយោបាយក្នុងតំបន់និងសកលអាចប៉ះពាល់ជាអវិជ្ជមានដល់លទ្ធភាពធនធានរបស់ដៃគូអភិវឌ្ឍន៍, ក៏ការបើកផ្តល់ហិរញ្ញប្បទាននៅបន្តកើនឡើងជាលំដាប់ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយដដែលនេះ ២០២១-២០២៥ ដើម្បីគាំទ្រដល់កិច្ចអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចកម្ពុជា ។ គួរកត់សម្គាល់ផងដែរថា ក្នុងរយៈពេលដូចគ្នានេះ, ឥណទានសម្បទានមានទំហំជាង ៩៥០ លានដុល្លារ ក្នុងឆ្នាំ២០២១ ហើយបន្តកើនឡើងជាលំដាប់ ពោលគឺជាង ១.១០០ លានដុល្លារ ក្នុងឆ្នាំ២០២២, ជាង ១.២០០ លានដុល្លារក្នុងឆ្នាំ២០២៣ និងជាង ១.៣០០ លានដុល្លារ ក្នុងឆ្នាំ២០២៤-

២០២៥ ទន្ទឹមនឹងទំហំថេរនៃហិរញ្ញប្បទានឥតសំណងក្នុងរង្វង់ ៩០០ លានដុល្លារជាមធ្យមក្នុងមួយឆ្នាំ ។

## ១. អនុបាតហិរញ្ញប្បទានធៀបនឹងផលិតផលក្នុងស្រុកសរុប និងហិរញ្ញប្បទានសម្រាប់ប្រជាជនម្នាក់

គំនូសទី ២.២ បង្ហាញថា អនុបាតហិរញ្ញប្បទានធៀបនឹងផលិតផលក្នុងស្រុកសរុប (ផ.ស.ស) បាននៅថេរក្នុងរង្វង់ ៥% ក្នុងឆ្នាំ២០២១-២០២៥ ។ អនុបាតហិរញ្ញប្បទានធៀបនឹង ផ.ស.ស មានប្រមាណ ៥% ក្នុងឆ្នាំ២០២១ ប៉ុន្តែថយចុះបន្តិចម្តងៗមកត្រឹម ៤% ក្នុងឆ្នាំ២០២៥។ តួលេខនេះរំពឹងថាអាចរក្សាភាពថេរ ឬទាបជាងនេះសម្រាប់រយៈពេលមធ្យមទៅមុខ ស្របពេលដែលកម្ពុជាកំពុងមានការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមយ៉ាងឆាប់រហ័ស ហើយត្រៀមខ្លួនចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ។ ទន្ទឹមនឹងនេះ, ហិរញ្ញប្បទានសម្រាប់ប្រជាជនម្នាក់នៅរក្សាបានទំហំជាមធ្យម ក្នុងរង្វង់ ១៣០ ដុល្លារ ក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយ ២០២៣-២០២៥ នេះ ។

**គំនូសទី ២.២ : អនុបាតហិរញ្ញប្បទានធៀបនឹងផលិតផលក្នុងស្រុកសរុប**



## ២. ការបើកផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍

តារាងទី ២.១ បង្ហាញថា ហិរញ្ញប្បទានបើកផ្តល់ដោយស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ (រួមមានធនាគារអភិវឌ្ឍន៍អាស៊ី, ធនាគារពិភពលោក និងមូលនិធិអន្តរជាតិផ្សេងៗ) មានទំហំជាង ៣០០ លានដុល្លារ ក្នុងឆ្នាំ២០២១ និងបានកើនដល់ជិត ៦០០ លានដុល្លារ ក្នុងមួយឆ្នាំ ក្នុងចន្លោះឆ្នាំ២០២២-២០២៤ ហើយរំពឹងថាអាចកើនដល់ ៨០០ លានដុល្លារ នៅឆ្នាំ២០២៥ ដោយសារការគ្រោងបើកផ្តល់របស់ធនាគារអភិវឌ្ឍន៍អាស៊ីសម្រាប់អនុវត្តគម្រោងធំៗ ចំនួន ៥ ដែលត្រូវបានអនុម័តក្នុងឆ្នាំ២០២៤ ។

ក្នុងបណ្តាស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ ធនាគារអភិវឌ្ឍន៍អាស៊ីបានបើកផ្តល់ច្រើនជាងគេ ។ ជាក់ស្តែង, បានបើកផ្តល់ប្រមាណ ៣៩៥ លានដុល្លារ ក្នុងឆ្នាំ២០២៣ និងប្រមាណ ៣៦១ លានដុល្លារ ក្នុងឆ្នាំ២០២៤ ហើយគ្រោងបន្តកើនឡើងដល់ប្រមាណជាង ៤៥៦ លានដុល្លារ ក្នុងឆ្នាំ២០២៥ ។ រីឯធនាគារពិភពលោកបានបើកផ្តល់ជិត ១៦០ លានដុល្លារ ក្នុងឆ្នាំ២០២៣ និង១៧៧ លានដុល្លារ ក្នុងឆ្នាំ២០២៤ និងគ្រោងបង្កើនការបើកផ្តល់ជិត ២៣០ លានដុល្លារ ក្នុងឆ្នាំ២០២៥ ។ ការបើកផ្តល់របស់ប្រព័ន្ធភ្នាក់ងារអង្គការសហប្រជាជាតិបានកើនឡើងពី ៨០ លានដុល្លារ ក្នុងឆ្នាំ២០២៣ ដល់ប្រមាណ ១០៥ លានដុល្លារ ក្នុងឆ្នាំ២០២៤ និងគ្រោងបន្តកើនឡើងដល់ ១៦០ លានដុល្លារ ក្នុងឆ្នាំ២០២៥។ ទន្ទឹមនឹងនេះ, ដៃគូអភិវឌ្ឍន៍ទ្វេភាគីបានបើកផ្តល់ហិរញ្ញប្បទានវង្វង់ ១.០០០ លានដុល្លារក្នុងមួយឆ្នាំ ក្នុងចន្លោះឆ្នាំ២០២១-២០២៥ ហើយអាចធ្លាក់ចុះមកប្រមាណ ៧៥០ លានដុល្លារ ក្នុងឆ្នាំ២០២៥។

សាធារណរដ្ឋប្រជាមានិតចិននៅតែជាដៃគូទ្វេភាគីផ្តល់ហិរញ្ញប្បទានច្រើនជាងគេ, បន្ទាប់មកគឺជប៉ុន និងសាធារណរដ្ឋកូរ៉េ ដែលមានហិរញ្ញប្បទានរួមបញ្ចូលគ្នាប្រមាណ ៤០% នៃហិរញ្ញប្បទានសរុបដែលបានបើកផ្តល់មកកម្ពុជា។ ដោយឡែក ដៃគូអឺរ៉ុបនិងសហភាពអឺរ៉ុបបានបើកផ្តល់ប្រមាណ ១៥០ លានដុល្លារ ក្នុងឆ្នាំ២០២៣ ហើយបានកើនលើស ២៥០ លានដុល្លារ ក្នុងឆ្នាំ២០២៤ ស្មើនឹងប្រមាណ ១៥% នៃហិរញ្ញប្បទានសរុប ។ សាធារណរដ្ឋបារាំងជាដៃគូបានផ្តល់ធនធានច្រើនជាងគេ ដោយបានបង្កើនពី ៥០ លានដុល្លារ ក្នុងឆ្នាំ២០២៣ ដល់ប្រមាណ ១៧០ លានដុល្លារ ក្នុងឆ្នាំ២០២៤ ។ បន្ទាប់មកគឺគណៈកម្មការអឺរ៉ុបដែលបានបើកផ្តល់ប្រមាណ ៥០ លានដុល្លារ ក្នុងមួយឆ្នាំ ក្នុងរយៈពេល ៣ ឆ្នាំចុងក្រោយនេះ ២០២៣-២០២៥ ហើយសង្ឃឹមថាអាចរក្សាទំហំនេះនៅក្នុងឆ្នាំ២០២៥ ។ រីឯសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់បានបើកផ្តល់ក្នុងរង្វង់ ៥០ លានដុល្លារក្នុងមួយឆ្នាំ ក្នុងរយៈពេល ៣ឆ្នាំចុងក្រោយដដែល ហើយសង្ឃឹមថាអាចកើនដល់ ៧០ លានដុល្លារ ក្នុងឆ្នាំ២០២៥ ។ ទោះយ៉ាងនេះក្តី បើពិនិត្យជារួមក្នុងឆ្នាំ២០២៥, ការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូអឺរ៉ុបអាចថមថយបន្តិចមកត្រឹមជាង ២០០ លានដុល្លារ ដោយសារគម្រោងអភិវឌ្ឍន៍មួយចំនួនត្រូវបានបើកផ្តល់តែមួយលើកក្នុងឆ្នាំ២០២៤ និងម្យ៉ាងទៀត ដោយសារគោលនយោបាយរឹតត្បិតធនធានរបស់ដៃគូអឺរ៉ុបមួយចំនួន, ភាពមិនប្រាកដប្រជា និងភាពតានតឹងនៃសង្គ្រាមពាណិជ្ជកម្មដែលកំពុងកើតមានឡើងនាពេលបច្ចុប្បន្ន ។

# តារាងទី ២.១ : ការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ (លានដុល្លារ)

| ដៃគូអភិវឌ្ឍន៍ | 2016-2020 | 2021 | 2022 | 2023 | 2024 | 2025 ប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| ភ្នាក់ងារអង្គការសហប្រជាជាតិ | | | | | | |
| ធនធានសរុប | 440.7 | 109.7 | 126.5 | 80.4 | 123.7 | 160.2 |
| ធនធានផ្ទាល់ | 335.9 | 89.3 | 108.3 | 80.4 | 105.3 | 160.2 |
| ដៃគូពហុភាគី | | | | | | |
| ធនាគារពិភពលោក | 236.5 | 73 | 312 | 158.5 | 177.6 | 228.5 |
| ធនាគារអភិវឌ្ឍន៍អាស៊ី | 1,070.3 | 204 | 240.3 | 394.5 | 361.7 | 455.7 |
| GAVI Alliance | 64 | 9.1 | - | - | - | - |
| IAEA | | - | 0.3 | - | - | - |
| មូលនិធិសកល | 161.7 | 29.6 | 39.2 | 44.1 | 34.5 | 32.4 |
| **សរុប** | **1,532.5** | **315.7** | **591.8** | **597.1** | **573.8** | **716.7** |
| សហភាពអឺរ៉ុប | | | | | | |
| គណៈកម្មការអឺរ៉ុប | 351.1 | 76.2 | 81.6 | 47.9 | 47.7 | 54.4 |
| សាធារណរដ្ឋឆែក | 7.7 | 2.5 | 2.9 | 2.5 | 2.2 | 1.8 |
| បារាំង | 484.6 | 117.8 | 58 | 49.7 | 169.8 | 79.2 |
| អាល្លឺម៉ង់ | 175.2 | 31.5 | 59.6 | 41.4 | 39.5 | 69.8 |
| អៀរឡង់ | 4 | 1.6 | 1.5 | 1.6 | 2.7 | - |
| ស៊ុយអែត | 137.9 | 22.7 | 17.2 | 14.9 | 11.7 | 0.5 |
| ចក្រភពអង់គ្លេស | 7 | 3.4 | 2 | 1.2 | 0.4 | 0.4 |
| **សរុប** | **1,167.6** | **255.7** | **222.6** | **159.2** | **273.9** | **206.2** |
| ដៃគូទ្វេភាគី | | | | | | |
| អូស្ត្រាលី | 234.5 | 64.8 | 43.4 | 48.7 | 46.2 | 43.9 |
| កាណាដា | 15.4 | 3.5 | 3.2 | 2.6 | 2.2 | 1.6 |
| សាធារណរដ្ឋប្រជាមានិតចិន | 2,073.4 | 420.9 | 235.9 | 386.1 | 268.3 | 286 |
| ជប៉ុន | 1,150.8 | 227.7 | 561.1 | 286.4 | 250.7 | 139 |
| នូវែលសេឡង់ | 27.1 | 7.8 | 3.8 | 10.9 | 7.5 | 5.5 |
| សាធារណរដ្ឋកូរ៉េ | 327.6 | 122.2 | 128.8 | 108.4 | 228.7 | 244.6 |
| ស្វីស | 73.3 | 16.8 | 13.8 | 17.9 | 18.1 | 14.7 |
| ថៃឡង់ | | 7.3 | 3.6 | - | - | - |
| សហរដ្ឋអាមេរិក | 452.7 | 105.3 | 116.6 | 133.6 | 118.6 | - |
| **សរុប** | **4,354.9** | **976.3** | **1110** | **994.6** | **940.3** | **735.4** |
| អង្គការមិនមែនរដ្ឋាភិបាល (ធនធានផ្ទាល់) | 1,313.7 | 258.9 | 260.7 | 275.6 | 293.5 | 277.5 |
| សរុបរួម | 8,704.6 | 1,896.1 | 2,293.4 | 2,106.9 | 2,186.9 | 2,096.0 |

## ៣. ការប្រែប្រួលសំខាន់ៗនៃការបើកផ្តល់ហិរញ្ញប្បទាន

គំនូរទី ២.៣ បានបង្ហាញថា ក្នុងឆ្នាំ២០២៣, យ៉ាងតិច ៥០% នៃការបើកផ្តល់ហិរញ្ញប្បទានសរុបមានប្រភពមកពីដៃគូ ៥ គឺៈ ធនាគារអភិវឌ្ឍន៍អាស៊ី, ចិន, ជប៉ុន, ធនាគារពិភពលោក និងសាធារណរដ្ឋកូរ៉េ ។ ដៃគូទាំងនេះនៅតែជាដៃគូធំជាងគេក្នុងឆ្នាំ២០២៤-២០២៥ ដែលបានបើកផ្តល់ក្នុងរង្វង់ ៦០% នៃហិរញ្ញប្បទានសរុប ។ ក្នុងឆ្នាំ២០២១-២០២៥, ធនាគារអភិវឌ្ឍន៍អាស៊ី និងសាធារណរដ្ឋប្រជាមានិតចិន គឺជាដៃគូដែលបានបើកផ្តល់ហិរញ្ញប្បទានច្រើនជាងគេ, បន្ទាប់មកគឺជប៉ុន ។ ការបើកផ្តល់ហិរញ្ញប្បទានរបស់សាធារណរដ្ឋប្រជាមានិតចិនបាន កើនខ្ពស់បំផុតក្នុងឆ្នាំ២០២១ ជាង ៤០០ លានដុល្លារ ។ រីឯការបើកផ្តល់ហិរញ្ញប្បទានខ្ពស់បំផុតរបស់ជប៉ុន គឺក្នុងឆ្នាំ២០២២ ដែលមានជាង ៥០០ លានដុល្លារ ។

**គំនូរទី ២.៣ : ការប្រៀបធៀបហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ (លានដុល្លារ)**



គំនូរទី ២.៤ បង្ហាញពីការកើនឡើងនៃឥណទានសម្បទានធៀបនឹងភាពនៅទ្រឹងនៃហិរញ្ញប្បទានឥតសំណងរបស់ដៃគូសំខាន់ៗមួយចំនួនក្នុងចន្លោះឆ្នាំ២០២៣-២០២៥។ ដៃគូដែលបានផ្តល់ហិរញ្ញប្បទានច្រើនលើសលុបរបស់ខ្លួនជាឥណទានសម្បទាន គឺធនាគារអភិវឌ្ឍន៍អាស៊ី, ចិន, ធនាគារពិភពលោក, ជប៉ុន និងសាធារណរដ្ឋកូរ៉េ ។ រីឯដៃគូដែលបានរក្សាទំហំហិរញ្ញប្បទានឥតសំណងទន្ទឹមនឹងការបង្កើនឥណទានសម្បទានគឺៈ ជប៉ុនដែលបានផ្តល់ក្នុងរង្វង់ ៥០-៨០ លានដុល្លារក្នុងមួយឆ្នាំ ក្នុងពេលដែលធនាគារអភិវឌ្ឍន៍អាស៊ី និងសាធារណរដ្ឋកូរ៉េបានផ្តល់ជាង ៥០ លានដុល្លារក្នុងមួយឆ្នាំ ក្នុងចន្លោះឆ្នាំ២០២៣-២០២៥ ។

**គំនូរទី ២.៤ : ការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍តាមទម្រង់ (លានដុល្លារ)**



## ៤. ការបើកផ្តល់ហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍តាមទម្រង់

តារាងទី ២.២ បង្ហាញអំពីទំហំហិរញ្ញប្បទានសរុប រួមទាំងឥណទានសម្បទាន និងហិរញ្ញប្បទានឥតសំណងរបស់ដៃគូសំខាន់ៗ, ក្នុងនោះ មានសាធារណរដ្ឋប្រជាមានិតចិន, ជប៉ុន, សាធារណរដ្ឋកូរ៉េ, ធនាគារអភិវឌ្ឍន៍អាស៊ី, សហភាពអឺរ៉ុប និងប្រទេសជាសមាជិក និងធនាគារពិភពលោក ។ តារាងទី ២.២ បានរំលេចអំពីធនធានផ្ទាល់របស់អង្គការមិនមែនរដ្ឋាភិបាល ។ ជាក់ស្តែង, ហិរញ្ញប្បទានឥតសំណងដែលមានទំហំប្រមាណ ៨៧០ លានដុល្លារ ក្នុងឆ្នាំ២០២៣ បានធ្លាក់ចុះបន្តិចមកត្រឹម ៨៥០ លានដុល្លារ ក្នុងឆ្នាំ២០២៤ និងអាចបន្តធ្លាក់ចុះមកត្រឹមប្រមាណ ៧៦០ លានដុល្លារ ក្នុងឆ្នាំ២០២៥ ។ និន្នាការថមថយចុះនៃការបើកផ្តល់ហិរញ្ញប្បទានឥតសំណងនឹងបន្តទៀតក្នុងរយៈពេលមធ្យមខាងមុខ។ ដោយឡែក ឥណទានសម្បទានបានបន្តកើនឡើងក្នុងបណ្តាឆ្នាំកន្លងមក ហើយសង្ឃឹមថានឹងបន្តកើនឡើងនាបណ្តាឆ្នាំខាងមុខ ។ ជាក់ស្តែងក្នុងឆ្នាំ២០២៣, ឥណទានសម្បទានមានទំហំប្រមាណ ១.២៤០ លានដុល្លារ ស្មើនឹង ៥៩% នៃហិរញ្ញប្បទានសរុប និងបានកើនដល់ ១.៣៤០ លានដុល្លារ ក្នុងឆ្នាំ២០២៤ ហើយអាចរក្សាទំហំនេះក្នុងឆ្នាំ២០២៥ ស្មើនឹងប្រមាណជាង ៦១% នៃហិរញ្ញប្បទានសរុប ។ ជារួម ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ, ការបើកផ្តល់ហិរញ្ញប្បទានឥតសំណង ធៀបនឹងឥណទានសម្បទាន ស្ថិតក្នុងសមាមាត្រ ៤០/៦០ ដែលស្ថានភាពនេះមានលក្ខណៈស្របទៅនឹងបរិវត្តកម្មសង្គម-សេដ្ឋកិច្ចរបស់កម្ពុជា និងការឈានទៅចាកចេញពីឋានៈជាប្រទេសមានការអភិវឌ្ឍតិចតួចនាដំណាច់ទសវត្សរ៍នេះ ។

## តារាងទី ២.២ : ការបើកផ្តល់ហិរញ្ញប្បទានតាមទម្រង់ (លានដុល្លារ)

| ដៃគូអភិវឌ្ឍន៍ | 2016-2020 | 2021 | 2022 | 2023 | 2024 | 2025 ប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| សាធារណៈរដ្ឋប្រជាមានិតចិន | | | | | | |
| Grant | 301.6 | 78.0 | 27.6 | 13.9 | 4.4 | 8.8 |
| Loan | 1,771.8 | 342.9 | 208.3 | 372.2 | 263.9 | 277.2 |
| **សរុប** | **2,073.4** | **420.9** | **235.9** | **386.1** | **268.3** | **286.0** |
| ជប៉ុន | | | | | | |
| Grant | 518.6 | 79.5 | 104.0 | 70.1 | 69.9 | 47.7 |
| Loan | 632.2 | 148.2 | 457.0 | 216.3 | 180.8 | 91.3 |
| **សរុប** | **1,150.8** | **227.7** | **561.1** | **286.4** | **250.7** | **139.0** |
| សហភាពអឺរ៉ុប និងសមាជិក | | | | | | |
| **Grant** | 744.7 | 151.3 | 178.2 | 117.9 | 110.0 | 130.8 |
| **Loan** | 423 | 104.4 | 44.5 | 41.4 | 163.9 | 75.4 |
| **សរុប** | **1,167.6** | **255.7** | **222.6** | **159.2** | **273.9** | **206.2** |
| ធនាគារអភិវឌ្ឍន៍អាស៊ី | | | | | | |
| Grant | 138.6 | 12.5 | 10.3 | 13.0 | 16.4 | 45.7 |
| Loan | 931.7 | 191.6 | 230.0 | 381.5 | 345.3 | 410.1 |
| **សរុប** | **1,070.3** | **204.0** | **240.3** | **394.5** | **361.7** | **455.7** |
| សាធារណរដ្ឋកូរ៉េ | | | | | | |
| Grant | 156.4 | 48.9 | 58.7 | 51.0 | 44.4 | 27.3 |
| Loan | 171.2 | 73.4 | 70.1 | 57.3 | 184.3 | 217.3 |
| **សរុប** | **327.6** | **122.2** | **128.8** | **108.4** | **228.7** | **244.6** |
| ធនាគារពិភពលោក | | | | | | |
| Grant | 24.5 | 0.5 | 1.1 | 4.7 | 17.3 | 22.3 |
| Loan | 212 | 72.4 | 310.8 | 153.8 | 160.3 | 206.2 |
| **សរុប** | **236.5** | **73.0** | **312.0** | **158.5** | **177.6** | **228.5** |
| ដៃគូអភិវឌ្ឍន៍ផ្សេងៗ | | | | | | |
| Grant | 1,317.5 | 311.4 | 295.1 | 322.8 | 295.9 | 195.4 |
| Loan | 47.1 | 22.0 | 37.1 | 15.4 | 36.6 | 62.9 |
| **សរុប** | **1,364.6** | **333.5** | **332.1** | **338.2** | **332.4** | **258.3** |
| អង្គការមិនមែនរដ្ឋាភិបាល (ធនធានផ្ទាល់) | | | | | | |
| Grant | 1,313.7 | 259.0 | 260.7 | 275.6 | 293.5 | 277.5 |
| **សរុប** | **1,313.7** | **259.0** | **260.7** | **275.6** | **293.5** | **277.5** |

| សរុប (ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល) | | | | | | |
|---|---|---|---|---|---|---|
| Grant | 4,515.6 | 941.1 | 935.8 | 868.9 | 851.8 | 755.5 |
| % Grant | 52% | 50% | 41% | 41% | 39% | 36% |
| Loan | 4,189 | 955.0 | 1357.7 | 1238.0 | 1335.1 | 1340.4 |
| % Loan | 48% | 50% | 59% | 59% | 61% | 64% |
| សរុបរួម | 8,704.6 | 1,896.1 | 2,293.4 | 2,106.9 | 2,186.9 | 2,096.0 |

## ៥. ការវិវត្តនៃការបើកផ្តល់ហិរញ្ញប្បទានតាមវិស័យ

តារាងទី ២.៣ បង្ហាញពីការបើកផ្តល់ហិរញ្ញប្បទានតាមវិស័យ ។ វិស័យហេដ្ឋារចនាសម្ព័ន្ធទទួលបានហិរញ្ញប្បទានច្រើនជាងគេ។ ជាក់ស្តែង ការបើកផ្តល់ហិរញ្ញប្បទានបានកើនពី ៦២០ លានដុល្លារ ក្នុងឆ្នាំ២០២២ ដល់ ៧១៤ លានដុល្លារ ក្នុងឆ្នាំ២០២៤, ក្នុងនោះ ប្រមាណជិត ៥០% ត្រូវបានប្រើប្រាស់សម្រាប់អភិវឌ្ឍវិស័យដឹកជញ្ជូន ។ វិស័យនេះនឹងទទួលបានហិរញ្ញប្បទានច្រើនជាបន្តទៀត ប្រមាណ ៦៤០ លានដុល្លារ ក្នុងឆ្នាំ២០២៥ ។ ដៃគូសំខាន់ៗដែលគាំទ្រដល់វិស័យហេដ្ឋារចនាសម្ព័ន្ធ គឺសាធារណរដ្ឋប្រជាមានិតចិន និងជប៉ុន ដែលបានបើកផ្តល់ ២១៤ លានដុល្លារ និង ១៩១ លានដុល្លារ ក្នុងឆ្នាំ២០២៤ ។ បន្ទាប់មកគឺវិស័យសេដ្ឋកិច្ច ដែលទទួលបានធនធានជិត ៦០០ លានដុល្លារ ក្នុងឆ្នាំ២០២៤ (គាំទ្រដល់វិស័យកសិកម្ម ប្រមាណ ៤០%) ហើយសង្ឃឹមថាអាចនឹងទទួលបានប្រមាណ ៥៦០ លានដុល្លារ ក្នុងឆ្នាំ២០២៥ ។ សម្រាប់វិស័យសង្គមកិច្ច ពោលគឺ វិស័យសុខាភិបាល, អប់រំ និងគាំពារសង្គម, ហិរញ្ញប្បទានបានកើនឡើងពីប្រមាណ ៥០០ លានដុល្លារ ក្នុងឆ្នាំ២០២៤ ដល់ ៥៨៣ លានដុល្លារ ក្នុងឆ្នាំ២០២៥ ។ ដៃគូអភិវឌ្ឍន៍ដែលឈានមុខក្នុងការគាំទ្រវិស័យនេះ មានធនាគារពិភពលោកដែលបានបើកផ្តល់ជាង ៦០ លានដុល្លារ និងសាធារណរដ្ឋកូរ៉េដែលបានបើកផ្តល់ក្នុងរង្វង់ ៣០ លានដុល្លារ ក្នុងឆ្នាំ២០២៤ ។

## តារាងទី ២.៣ : ការបើកផ្តល់ហិរញ្ញប្បទានតាមវិស័យ (លានដុល្លារ)

| វិស័យ | 2016-2020 | 2021 | 2022 | 2023 | 2024 | 2025 ប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| **វិស័យសង្គមកិច្ច** | | | | | | |
| សុខាភិបាល | 1,162.3 | 278.2 | 254.4 | 269.6 | 251.7 | 370.8 |
| អប់រំ | 1,022.1 | 197.9 | 209.7 | 249.7 | 235.1 | 207.2 |
| គាំពារសង្គម | 59.2 | 8.4 | 12.7 | 12.7 | 12.8 | 5.3 |
| **សរុប** | **2,243.4** | **484.5** | **476.9** | **532.1** | **499.7** | **583.3** |
| **វិស័យសេដ្ឋកិច្ច** | | | | | | |
| កសិកម្ម | 1,046 | 282.6 | 265.1 | 221.0 | 242.0 | 249.5 |
| កម្មន្តសាល និងពាណិជ្ជកម្ម | 50.3 | 12.1 | 9.7 | 62.0 | 88.0 | 34.1 |
| អភិវឌ្ឍន៍ជនបទ | 403.6 | 88.8 | 166.4 | 117.4 | 196.4 | 195.4 |
| សេវាធុរកិច្ច និងហិរញ្ញវត្ថុ | 39.8 | 1.7 | 44.2 | 4.0 | 2.9 | 0.8 |
| នគរូបនីយកម្ម និងការគ្រប់គ្រង | 126.4 | 42.2 | 62.2 | 66.7 | 63.1 | 75.0 |
| **សរុប** | **1,666.1** | **427.4** | **547.8** | **471.2** | **592.8** | **554.9** |
| **វិស័យហេដ្ឋារចនាសម្ព័ន្ធ** | | | | | | |
| ព័ត៌មាន និងទូរគមនាគមន៍ | 18.9 | 6.6 | 6.9 | 10.9 | 17.5 | 1.7 |
| ថាមពល និងអគ្គិសនី | 850.6 | 148.1 | 56.1 | 140.3 | 156.7 | 170.2 |
| ការដឹកជញ្ជូន | 1,580.8 | 371.4 | 480.7 | 533.3 | 336.7 | 273.5 |
| ទឹកស្អាត និងអនាម័យ | 410.6 | 170.1 | 76.2 | 117.6 | 202.9 | 195.5 |
| **សរុប** | **2,860.9** | **696.2** | **620.0** | **802.3** | **714.0** | **641.1** |
| **អន្តរវិស័យ** | | | | | | |
| ការអភិវឌ្ឍន៍សហគមន៍ | 363.9 | 94.3 | 93.8 | 74.9 | 77.3 | 70.8 |
| វប្បធម៌ និងសិល្បៈ | 158.9 | 21.0 | 6.1 | 7.6 | 3.8 | 1.7 |
| បរិស្ថាន និងចីរភាព | 177.4 | 35.3 | 39.4 | 51.9 | 48.2 | 35.9 |
| ការប្រែប្រួលអាកាសធាតុ | 51 | 5.0 | 6.2 | 7.1 | 10.3 | 10.2 |
| យេនឌ័រ | 28.5 | 5.1 | 6.0 | 5.3 | 6.9 | 11.2 |
| មេរោគហ៊ីវ/ជំងឺអេដស៍ | 82.4 | 5.6 | 10.1 | 10.8 | 11.5 | 10.0 |
| អភិបាលកិច្ច និងរដ្ឋបាល | 434.9 | 88.6 | 76.2 | 115.0 | 125.0 | 32.6 |
| ទេសចរណ៍ | 31 | 6.8 | 5.8 | 1.7 | 1.4 | 1.6 |
| ការទ្រទ្រង់ថវិកា និងជញ្ជីងទូទាត់ | 245.4 | 9.5 | 184.5 | 5.8 | 50.0 | - |
| ជំនួយសង្គ្រោះបន្ទាន់ និងស្បៀងអាហារ | 6.2 | 8.5 | 3.2 | 1.2 | 0.1 | - |
| **សរុប** | **1,579.3** | **279.7** | **431.7** | **281.6** | **335.0** | **174.2** |
| ផ្សេងៗ | 356.8 | 8.2 | 216.8 | 19.4 | 45.2 | 142.1 |
| សរុបរួម | 8,706.7 | 1,896.1 | 2,293.4 | 2,106.8 | 2,186.8 | 2,095.9 |

## ៦. ហិរញ្ញប្បទានសម្រាប់អន្តរវិស័យ

តារាងទី ២.៤ បង្ហាញថា ទំហំហិរញ្ញប្បទានសម្រាប់ការអនុវត្តគម្រោងដែលបានបញ្ជ្រាបការប្រែប្រួលអាកាសធាតុ បានកើនឡើងពីជាង ៣០០ លានដុល្លារ ក្នុងឆ្នាំ២០២៣ ដល់ប្រមាណ ៣៥០ លានដុល្លារ ក្នុងឆ្នាំ២០២៤ និងជាង ៣៨០ លានដុល្លារ ក្នុងឆ្នាំ២០២៥ ។ ហិរញ្ញប្បទានសម្រាប់ការបញ្ជ្រាបសមភាពយេនឌ័រមានទំហំប្រមាណ ៤០០ លានដុល្លារ ក្នុងឆ្នាំ២០២៣ ហើយបន្តកើនឡើងដល់ជាង ៥០០ លានដុល្លារ ក្នុងឆ្នាំ២០២៥ ។ ដោយឡែក, ហិរញ្ញប្បទានដែលបញ្ជ្រាបការគាំទ្រការអភិវឌ្ឍវិស័យឯកជន មានទំហំជាង ៥០០ លានដុល្លារ ក្នុងឆ្នាំ២០២៣ ប៉ុន្តែត្រូវបានប៉ាន់ស្មានថាអាចធ្លាក់ចុះមកត្រឹម ៤០០ លានដុល្លារ ក្នុងឆ្នាំ២០២៥នេះ ។

**តារាងទី ២.៤: ការបើកផ្តល់ហិរញ្ញប្បទានសម្រាប់អន្តរវិស័យ (លានដុល្លារ)**

| អន្តរវិស័យ | 2021 | 2022 | 2023 | 2024 | 2025 ប៉ាន់ស្មាន | 2021-2025 |
|---|---|---|---|---|---|---|
| ការប្រែប្រួលអាកាសធាតុ | 321.1 | 240.5 | 317.6 | 355.9 | 389.9 | 1,625.3 |
| សមភាពយេនឌ័រ | 335.5 | 515.9 | 402.3 | 454.5 | 545.9 | 2,254.3 |
| ការអភិវឌ្ឍវិស័យឯកជន | 457.6 | 476.1 | 554.1 | 481.2 | 399.9 | 2,369.1 |
| សរុប | 1,114.3 | 1,232.7 | 1,274.1 | 1291.7 | 1,335.8 | 6,248.7 |

## ៧. ការចូលរួមរបស់ដៃគូអភិវឌ្ឍន៍ក្នុងក្រុមការងារបច្ចេកទេសចម្រុះ

តារាងទី ២.៥ បង្ហាញថា ក្នុងចន្លោះឆ្នាំ ២០២១-២០២៥, ក្រុមការងារបច្ចេកទេសចម្រុះបានសម្របសម្រួល ២១៤ គម្រោង ដែលមានហិរញ្ញប្បទានជាមធ្យមប្រមាណ ១.២២៧ លានដុល្លារ ក្នុងមួយឆ្នាំ ។ ចំនួនគម្រោងដែលក្រុមការងារបច្ចេកទេសចម្រុះបានសម្របសម្រួលច្រើនជាងគេ គឺនៅក្នុងវិស័យសង្គមកិច្ចចំនួន ៧៦ គម្រោង ដែលមានហិរញ្ញប្បទានប្រមាណ ៣២៣ លានដុល្លារ ជាមធ្យមក្នុងមួយឆ្នាំ ។ ក្រុមការងារបច្ចេកទេសចម្រុះស្តីពីវិស័យហេដ្ឋា-

វេចនាសម្ព័ន្ធបានសម្របសម្រួល ១៥ គម្រោង ដែលមានធនធានរហូតដល់ ៦២២ លានដុល្លារ ជាមធ្យមក្នុងមួយឆ្នាំ ។ ក្រុមការងារបច្ចេកទេសចម្រុះស្តីពីវិស័យសុខាភិបាលបានសម្របសម្រួល ៣៥ គម្រោង ដែលមានធនធាន ១២៩ លានដុល្លារ និងក្រុមការងារបច្ចេកទេសចម្រុះស្តីពីវិស័យអប់រំបានសម្របសម្រួល ២០ គម្រោងដែលមានហិរញ្ញប្បទាន ៧៤ លានដុល្លារ។ ដោយឡែក, ក្រុមការងារបច្ចេកទេសចម្រុះស្តីពីទឹកស្អាត និងអនាម័យជនបទបានសម្របសម្រួល ៤ គម្រោង ដែលមានហិរញ្ញប្បទាន ៦២ លានដុល្លារ។ រីឯសម្រាប់វិស័យសេដ្ឋកិច្ច, ក្រុមការងារបច្ចេកទេសចម្រុះបានសម្របសម្រួល ៦៩ គម្រោង ដែលមានហិរញ្ញប្បទាន ២២១ លានដុល្លារ, ក្នុងនោះ ក្រុមការងារបច្ចេកទេសចម្រុះស្តីពីវិស័យកសិកម្មនិងទឹកបានសម្របសម្រួល ៤០ គម្រោង ដែលមានហិរញ្ញប្បទាន ១៥១ លានដុល្លារ ។

**តារាងទី ២.៥ : ការបើកផ្តល់ហិរញ្ញប្បទានតាមក្រុមការងារបច្ចេកទេសចម្រុះ (លានដុល្លារ)**

| ក្រុមការងារ បច្ចេកទេសចម្រុះ | 2021 | 2022 | 2023 | 2024 | 2025 ប៉ាន់ស្មាន | ចំនួនដៃគូ | ចំនួនគម្រោង | 2021-2025 (មធ្យមភាគ) |
|---|---|---|---|---|---|---|---|---|
| **វិស័យសង្គមកិច្ច** | | | | | | | | |
| សុខាភិបាល | 138.2 | 121.1 | 90.4 | 106.0 | 188.8 | 14 | 35 | 128.9 |
| ហ៊ីវ/អេដស៍ | 21.0 | 32.3 | 34.8 | 25.5 | 22.8 | 2 | 3 | 27.3 |
| អប់រំ | 68.2 | 88.2 | 91.2 | 60.7 | 63.0 | 9 | 20 | 74.3 |
| សន្តិសុខស្បៀង និងអាហារូបត្ថម្ភ | 8.9 | 9.1 | 5.6 | 0.9 | 2.7 | 2 | 3 | 5.4 |
| ទឹកស្អាត និងអនាម័យជនបទ | 33.0 | 45.0 | 35.5 | 127.3 | 72.9 | 4 | 4 | 62.7 |
| បណ្តុះបណ្តាល និងវិជ្ជាជីវៈ | 9.6 | 7.8 | 28.7 | 36.4 | 41.4 | 8 | 11 | 24.8 |
| **សរុប** | **279.0** | **303.6** | **286.3** | **356.9** | **391.5** | **39** | **76** | **323.4** |

| ក្រុមការងារ បច្ចេកទេសចម្រុះ | 2021 | 2022 | 2023 | 2024 | 2025 ប៉ាន់ស្មាន | ចំនួន ដៃគូ | ចំនួន គម្រោង | 2021-2025 (មធ្យមភាគ) |
|---|---|---|---|---|---|---|---|---|
| **វិស័យសេដ្ឋកិច្ច** | | | | | | | | |
| កសិកម្ម និងទឹក | 189.1 | 191.5 | 97.2 | 141.8 | 138.8 | 9 | 40 | 151.7 |
| នេសាទ | 26.1 | 20.9 | 34.7 | 22.3 | 38.4 | 5 | 12 | 28.5 |
| ព្រៃឈើ | 6.6 | 7.8 | 18.0 | 5.6 | 7.9 | 5 | 11 | 9.2 |
| ការគ្រប់គ្រងដីធ្លី | - | - | - | - | - | - | - | 0 |
| ការកំចាត់មីន | 16.0 | 19.7 | 21.9 | 19.1 | 8.7 | 4 | 4 | 17.1 |
| ការអភិវឌ្ឍវិស័យឯកជន | 11.5 | 17.6 | 18.9 | 18.2 | 11.1 | 2 | 2 | 15.5 |
| **សរុប** | **249.4** | **257.6** | **190.7** | **207.0** | **205** | **35** | **69** | **221.9** |
| **វិស័យហេដ្ឋារចនាសម្ព័ន្ធ** | | | | | | | | |
| ហេដ្ឋារចនាសម្ព័ន្ធ និងសមាហរណកម្មតំបន់ | 672.0 | 614.6 | 719.3 | 609.5 | 497.8 | 4 | 15 | 622.6 |
| **សរុប** | **672.0** | **614.6** | **719.3** | **609.5** | **497.8** | **4** | **15** | **622.6** |
| **អន្តរវិស័យ និងរដ្ឋបាល** | | | | | | | | |
| ការកែទម្រង់រដ្ឋបាលសាធារណៈ | 0.9 | 0.5 | 0.0 | 0.0 | 0.1 | 1 | 1 | 0.3 |
| ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | 20.1 | 6.9 | 12.4 | 59.8 | 6.8 | 3 | 5 | 21.2 |
| វិមជ្ឈការ និងវិសហមជ្ឈការ | 9.2 | 8.6 | 15.8 | 15.5 | 11.9 | 6 | 9 | 12.2 |
| យេនឌ័រ | 12.2 | 15.1 | 12.1 | 6.6 | 9.5 | 7 | 14 | 11.1 |
| ការកែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ | 4.4 | 1.7 | 0.4 | 0.6 | 0.9 | 2 | 2 | 1.6 |

| ក្រុមការងារ បច្ចេកទេសចម្រុះ | 2021 | 2022 | 2023 | 2024 | 2025 ប៉ាន់ស្មាន | ចំនួនដៃគូ | ចំនួនគម្រោង | 2021-2025 (មធ្យមភាគ) |
|---|---|---|---|---|---|---|---|---|
| ភាពជាដៃគូ និងសុខដុមនីយកម្ម | 0.0 | 0.2 | 0.0 | 0.0 | - | 1 | 1 | 0.0 |
| ផែនការ និងការកាត់បន្ថយភាពក្រីក្រ | 12.7 | 6.4 | 4.9 | 5.1 | 2.7 | 5 | 5 | 6.3 |
| ការប្រែប្រួលអាកាសធាតុ | 3.7 | 3.1 | 5.6 | 10.0 | 12.1 | 5 | 17 | 6.9 |
| **សរុប** | **63.2** | **42.4** | **51.0** | **97.6** | **44** | **30** | **54** | **59.6** |
| **សរុបរួមទី១** | **1,263.6** | **1,218.2** | **1,247.3** | **1,271** | **1,138.1** | **98** | **214** | **1,227.7** |
| គម្រោង/ហិរញ្ញប្បទានមិនស្ថិតនៅក្រោមការសម្របសម្រួលរបស់ក្រុមការងារ | 183.8 | 352.2 | 167.6 | 203.8 | 120 | 14 | 250 | 205.4 |
| **សរុបរួមទី២** | **1,447.3** | **1,570.4** | **1,414.9** | **1,474.9** | **1,258.1** | **112** | **464** | **1,433.1** |

តារាងទី ២.៦ បង្ហាញថា ជប៉ុនគឺជាដៃគូអភិវឌ្ឍន៍ដែលបានចូលរួមច្រើនជាងគេក្នុងក្រុមការងារបច្ចេកទេសចម្រុះ ដោយមានគម្រោងចំនួន ១៤៥ ។ បន្ទាប់មកគឺ សាធារណរដ្ឋកូរ៉េ ចំនួន ២៦ គម្រោង ធនាគារអភិវឌ្ឍន៍អាស៊ី និងបារាំង មានចំនួន ១៩ គម្រោង ព្រមទាំងសហភាពអឺរ៉ុបចំនួន ១៨ គម្រោង ។ សាធារណរដ្ឋប្រជាមានិតចិនបើកផ្តល់ហិរញ្ញប្បទាន ៣៨០ លានដុល្លារ ក្នុងឆ្នាំ២០២៣ និងក្នុងរង្វង់ ២៧០ លានដុល្លារក្នុងមួយឆ្នាំ ក្នុងឆ្នាំ២០២៤-២០២៥ សម្រាប់គាំទ្រទៅដល់បណ្តាវិស័យ ដែលសម្របសម្រួលដោយក្រុមការងារបច្ចេកទេសចម្រុះ ។ រីឯជប៉ុនបានបើកផ្តល់ហិរញ្ញប្បទាន ២៧៤ លានដុល្លារក្នុងឆ្នាំ២០២៣ និងធ្លាក់មកត្រឹម ២១០ លានដុល្លារ ក្នុងឆ្នាំ២០២៤ និង ១២០ លានដុល្លារ ក្នុងឆ្នាំ២០២៥ សម្រាប់គាំទ្រដល់បណ្តាវិស័យដែលសម្របសម្រួលដោយក្រុមការងារបច្ចេកទេសចម្រុះ។ ដោយឡែក, ធនាគារអភិវឌ្ឍន៍អាស៊ីបើកផ្តល់ហិរញ្ញប្បទានជិត ១៨០ លានដុល្លារ ក្នុងឆ្នាំ២០២៣ និងជិត ១៩៥

លានដុល្លារ ក្នុងឆ្នាំ២០២៤ និង ២៣០ លានដុល្លារ ក្នុងឆ្នាំ២០២៥ សម្រាប់គាំទ្រដល់បណ្តាវិស័យដែលសម្របសម្រួលដោយក្រុមការងារបច្ចេកទេសចម្រុះ ។

**តារាងទី ២.៦ : ដៃគូអភិវឌ្ឍន៍សំខាន់ៗក្នុងក្រុមការងារបច្ចេកទេសចម្រុះ (លានដុល្លារ)**

| ដៃគូអភិវឌ្ឍន៍ | ចំនួនគម្រោង | 2021 | 2022 | 2023 | 2024 | 2025 ប៉ាន់ស្មាន |
|---|---|---|---|---|---|---|
| សាធារណរដ្ឋប្រជាមានិតចិន | 12 | 394.8 | 234.5 | 381.0 | 263.9 | 277.2 |
| ជប៉ុន | 145 | 198.8 | 519.7 | 273.6 | 212.9 | 119.9 |
| ធនាគារអភិវឌ្ឍន៍អាស៊ី | 19 | 166.3 | 183.5 | 176.5 | 194.2 | 228.2 |
| ធនាគារពិភពលោក | 10 | 67.9 | 105.2 | 137.8 | 167.1 | 175.7 |
| បារាំង | 19 | 115.5 | 57.0 | 49.5 | 168.7 | 79.2 |
| សាធារណរដ្ឋកូរ៉េ | 26 | 107.8 | 82.8 | 63.8 | 185.7 | 166.6 |
| សហភាពអឺរ៉ុប | 18 | 72.4 | 79.4 | 44.5 | 39.0 | 40.4 |
| អូស្ត្រាលី | 14 | 50.1 | 25.5 | 20.3 | 13.7 | 13.6 |
| មូលនិធិសកល | 5 | 29.6 | 39.2 | 44.1 | 34.5 | 32.4 |
| អង្គការ UNICEF | 5 | 27.9 | 28.3 | 23.9 | 21.9 | 17.4 |
| ផ្សេងៗ | 191 | 216.4 | 215.3 | 199.7 | 173.2 | 107.5 |
| សរុប | 464 | 1,447.3 | 1,570.4 | 1,414.9 | 1,474.9 | 1,258.1 |

## ៨. ការបើកផ្តល់ហិរញ្ញប្បទានតាមរាជធានី-ខេត្ត

ផ្នែកនេះបង្ហាញអំពីការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍តាមរាជធានី-ខេត្ត ដែលអាចផ្តល់ព័ត៌មានស្តីពីហិរញ្ញប្បទានតាមភូមិសាស្ត្រ និងសម្រាប់ជាមូលដ្ឋានពង្រឹងកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមសេចក្តីណែនាំស្តីពីកិច្ចពិគ្រោះយោបល់ភាពជាដៃគូនៅថ្នាក់ក្រោមជាតិនៃយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ។ ក្នុងឆ្នាំ២០២១-២០២៥, រាជធានី និងខេត្តចំនួន ៥ គឺ៖ ភ្នំពេញ, សៀមរាប, បាត់ដំបង, កំពង់ចាម និងបន្ទាយមានជ័យ ទទួលបានហិរញ្ញប្បទានសរុបរហូតដល់ប្រមាណ ៣០% នៃហិរញ្ញប្បទានសរុប ។ ទន្ទឹមនឹងនេះ, គម្រោងដែលមានវិសាលភាពទូទាំងប្រទេស មានប្រមាណ ៤០% នៃហិរញ្ញប្បទានសរុប។

ជារួម ជិតពាក់កណ្តាលនៃហិរញ្ញប្បទានសរុបត្រូវបានបើកផ្តល់សម្រាប់គម្រោងក្នុងខេត្តចំនួន ២០ ដែលការណ៍នេះបង្ហាញពីការទទួលបានផលប្រយោជន៍ស្មើរគ្រប់តំបន់នៃព្រះរាជាណាចក្រកម្ពុជាពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នេះ ។

**តារាងទី ២.៧ : ការបើកផ្តល់ហិរញ្ញប្បទានតាមរាជធានី-ខេត្ត (លានដុល្លារ)**

| រាជធានី-ខេត្ត | 2021 | 2022 | 2023 | 2024 | 2025 ប៉ាន់ស្មាន | % ធៀបនឹងសរុប |
|---|---|---|---|---|---|---|
| ទូទាំងប្រទេស | 439.5 | 696.1 | 689.5 | 695.5 | 534.8 | 30% |
| ភ្នំពេញ | 339.7 | 181.3 | 190.7 | 298.2 | 131.4 | 11% |
| បាត់ដំបង | 138.1 | 174.5 | 88.6 | 88.2 | 83.3 | 6% |
| សៀមរាប | 137.3 | 123.8 | 143.1 | 131.9 | 94.4 | 6% |
| បន្ទាយមានជ័យ | 63.4 | 94.8 | 55.9 | 71.1 | 64.8 | 3% |
| កំពង់ចាម | 93.8 | 60.0 | 82.8 | 91.3 | 113.2 | 4% |
| ខេត្តដទៃទៀត | 684.3 | 953.4 | 844.9 | 808.4 | 869.4 | 40% |
| សរុប | 1,896 | 2,293 | 2,107 | 2,187 | 1,891 | 100% |

## ៩. ការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងកិច្ចអភិវឌ្ឍន៍ជាតិ

ការប្រើប្រាស់ធនធានរបស់អង្គការមិនមែនរដ្ឋាភិបាល ត្រូវបានកត់ត្រាក្នុងប្រព័ន្ធទិន្នន័យស្តីពីអង្គការមិនមែនរដ្ឋាភិបាលរបស់ ក.អ.ក ដើម្បីពិនិត្យលំហូរ និងតម្រឹមធនធានរបស់ពួកគេសម្រាប់គាំទ្រការអនុវត្តសកម្មភាពអាទិភាពតាមវិស័យរបស់រាជរដ្ឋាភិបាល និងដើម្បីលើកកម្ពស់តម្លាភាព និងស័ក្តិសិទ្ធភាពក្នុងការប្រើប្រាស់ធនធានទាំងនេះ។ ជាទូទៅ ធនធានសម្រាប់គាំទ្រសកម្មភាពរបស់អង្គការមិនមែនរដ្ឋាភិបាលមាន ២ ប្រភពគឺ៖ ធនធានដែលអង្គការមិនមែនរដ្ឋាភិបាលកៀរគរដោយផ្ទាល់ ដូចជាពីសប្បុរសជន វិភាគទាន មូលនិធិ និងអំណោយជាដើម (ហៅថាធនធានផ្ទាល់) និងធនធានដែលដៃគូអភិវឌ្ឍន៍បានផ្តល់ដល់អង្គការទាំងនេះសម្រាប់សកម្មភាពជាក់លាក់ ឬសម្រាប់អនុវត្តគម្រោងក្នុងឋានៈជាភ្នាក់ងារអនុវត្ត ។

គំនូរទី ២.៥ បានបង្ហាញថា ក្នុងឆ្នាំ២០២៣-២០២៥, ធនធានសរុបរបស់អង្គការមិនមែនរដ្ឋាភិបាលមានជាមធ្យមជិត ៤០០ លានដុល្លារ ក្នុងមួយឆ្នាំ, ក្នុងនោះ ធនធានផ្ទាល់មានប្រមាណ ២៨០ លានដុល្លារ ស្មើនឹងជិត ២/៣ នៃធនធានសរុប ។ គួរកត់សម្គាល់ដែរថា ក្នុងឆ្នាំ២០២៤, ធនធានរបស់អង្គការមិនមែនរដ្ឋាភិបាលមានប្រមាណ ៤៤០ លានដុល្លារ ហើយមានទំហំលើសពីឆ្នាំ២០២៣ ដែលមាន ៤៣០ លានដុល្លារ ។ សម្រាប់ឆ្នាំ២០២៥, ធនធានសរុបរបស់អង្គការមិនមែនរដ្ឋាភិបាលត្រូវបានប៉ាន់ស្មានថាអាចនឹងមានប្រហែល ៣៣០ លានដុល្លារ, ក្នុងនោះ ធនធានដែលបានពីដៃគូសម្រាប់អនុវត្តគម្រោងអាចមានប្រមាណ ៥០ លានដុល្លារ ដោយសារគោលនយោបាយត្បិតត្បៀតផ្តល់ហិរញ្ញប្បទានរបស់ប្រទេសជាដៃគូមួយចំនួន និងការមិនរាប់បញ្ចូលធនធានរបស់សហរដ្ឋអាមេរិក ប្រមាណ ១០០ លានដុល្លារ ដែលធ្លាប់ប្រើប្រាស់អង្គការមិនមែនរដ្ឋាភិបាលជាភ្នាក់ងារអនុវត្តគម្រោង ។

**គំនូរទី ២.៥ : ធនធានសរុបរបស់អង្គការមិនមែនរដ្ឋាភិបាល (លានដុល្លារ)**



តារាងទី ២.៨ បង្ហាញថា ក្នុងឆ្នាំ២០២៤, អង្គការមិនមែនរដ្ឋាភិបាលបានប្រើប្រាស់ធនធានច្រើនសម្រាប់គាំទ្រវិស័យសុខាភិបាល (រួមទាំងយុទ្ធនាការ និងកម្មវិធីប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ផងដែរ) ដែលមានប្រមាណ ១៣១ លានដុល្លារ ។ បន្ទាប់មកគឺវិស័យអប់រំដែលមានធនធានសរុប ១១០ លានដុល្លារ, ការអភិវឌ្ឍសហគមន៍ ៦០ លានដុល្លារ និងការអភិវឌ្ឍជនបទ ៤៥ លានដុល្លារ។ ជារួម ធនធានដែលប្រើប្រាស់ក្នុងវិស័យអាទិភាពចម្បងទាំង ៤ ខាងលើ មានប្រមាណ ៣៤០ លានដុល្លារ គឺស្មើនឹងប្រមាណ ៨០% នៃទំហំធនធានសរុបរបស់អង្គការមិនមែនរដ្ឋាភិបាល ។

**តារាងទី ២.៨ : ធនធានរបស់អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យ (លានដុល្លារ)**

| វិស័យ | 2023 | | | 2024 | | | 2025 ប៉ាន់ស្មាន | | |
|---|---|---|---|---|---|---|---|---|---|
| | ធនធានផ្ទាល់ | ធនធានដៃគូ | សរុប | ធនធានផ្ទាល់ | ធនធានដៃគូ | សរុប | ធនធានផ្ទាល់ | ធនធានដៃគូ | សរុប |
| សុខាភិបាល | 79.6 | 39.6 | 119.2 | 80.8 | 35.3 | 116.1 | 82.0 | 10.3 | 92.3 |
| អប់រំ | 78.2 | 24.6 | 102.8 | 88.8 | 21.7 | 110.5 | 75.5 | 7.3 | 82.8 |
| ការអភិវឌ្ឍសហគមន៍ | 53.2 | 5.7 | 58.9 | 56.1 | 5.1 | 61.2 | 54.9 | 2.5 | 57.4 |
| ការអភិវឌ្ឍជនបទ | 20.9 | 21.4 | 42.3 | 19.6 | 26.5 | 46.1 | 22.0 | 12.5 | 34.5 |
| អភិបាលកិច្ច | 4.1 | 30.4 | 34.5 | 2.7 | 29.3 | 32.0 | 2.0 | 3.9 | 5.9 |
| បរិស្ថាន | 17.2 | 6.6 | 23.8 | 22.2 | 6.8 | 29.0 | 19.5 | 3.3 | 22.8 |
| កសិកម្ម | 9.7 | 7.0 | 16.7 | 9.9 | 6.3 | 16.2 | 9.0 | 2.5 | 11.5 |
| ហ៊ីវ/អេដស៍ | 9.3 | 4.7 | 14.0 | 9.9 | 4.9 | 14.8 | 9.3 | 0.8 | 10.1 |
| ផ្សេងៗ | 3.7 | 9.7 | 13.4 | 3.6 | 7.9 | 11.5 | 3.5 | 5.0 | 8.5 |
| សរុប | 275.9 | 149.7 | 425.7 | 293.7 | 143.8 | 437.5 | 277.6 | 48.1 | 325.7 |

គំនូរទី ២.៦ បង្ហាញថា ក្នុងឆ្នាំ២០២៣-២០២៥, អង្គការមិនមែនរដ្ឋាភិបាលបានប្រើប្រាស់ធនធានផ្ទាល់ប្រហាក់ប្រហែលគ្នាសម្រាប់គាំទ្រវិស័យសុខាភិបាល និងវិស័យអប់រំ ហើយមានប្រមាណ ៨០% ធៀបនឹងធនធានសរុបសម្រាប់វិស័យនីមួយៗ ។ ទន្ទឹមនឹងនេះ, ធនធានដែលដៃគូអភិវឌ្ឍន៍បានផ្តល់ឱ្យអង្គការមិនមែនរដ្ឋាភិបាលសម្រាប់អនុវត្តគម្រោងវិស័យសុខាភិបាល មានទំហំធំជាងវិស័យអប់រំប្រមាណ ១០ លានដុល្លារ ។ រីឯគំនូរទី ២.៧ បង្ហាញថា ក្នុងឆ្នាំ២០២៣-២០២៥, ធនធានដែលអង្គការមិនមែនរដ្ឋាភិបាលទទួលបានពីដៃគូសម្រាប់អនុវត្តគម្រោងពាក់ព័ន្ធនឹងវិស័យអភិបាលកិច្ច មានរហូតដល់ជិត ៩០% ធៀបនឹងធនធានសរុបសម្រាប់ធ្វើសកម្មភាពក្នុងវិស័យនេះ ។ ផ្ទុយទៅវិញ ក្នុងការអភិវឌ្ឍសហគមន៍, អង្គការមិនមែនរដ្ឋាភិបាលទទួលបានធនធានតិចតួចពីដៃគូប្រមាណ ៧% នៃធនធានសរុប សម្រាប់អនុវត្តគម្រោងក្នុងវិស័យនេះ ។

**គំនូរទី ២.៦ : ការគាំទ្ររបស់អង្គការមិនមែនរដ្ឋាភិបាលតាមវិស័យ ឆ្នាំ២០២៣-២០២៥**



**គំនូរទី ២.៧ : ភាគរយនៃធនធានរបស់អង្គការមិនមែនរដ្ឋាភិបាល ឆ្នាំ២០២៣-២០២៥**




តារាងទី ២.៩ បង្ហាញថា ក្នុងឆ្នាំ២០២៣-២០២៥, អង្គការមិនមែនរដ្ឋាភិបាលចំនួន ៣០ បានប្រើប្រាស់ធនធានជាងពាក់កណ្ដាលនៃធនធានសរុប (ទាំងធនធានផ្ទាល់ និងធនធានរបស់ដៃគូ)។ អង្គការទស្សនៈពិភពលោក និងមូលនិធិគន្ធបុប្ផា បានកៀគរ និងប្រើប្រាស់ធនធានច្រើន, ក្នុងនោះ ប្រមាណជាង ៨០% នៃធនធានសរុប គឺជាធនធានផ្ទាល់ដែលកៀរគរបាន។ ជាក់ស្ដែងក្នុងឆ្នាំ២០២៤, អង្គការទស្សនៈពិភពលោកបានប្រើប្រាស់ធនធានជាង ៣០ លានដុល្លារ, ក្នុងនោះ ធនធានផ្ទាល់ជាង ២៥ លានដុល្លារ ។ រីឯមូលនិធិគន្ធបុប្ផា បានប្រើប្រាស់ធនធានជិត ២៩ លានដុល្លារ, ក្នុងនោះ ធនធានផ្ទាល់ជាង ២៥ លានដុល្លារ (តួលេខនេះមិនរាប់បញ្ចូលធនធានដែលទទួលពីរាជរដ្ឋាភិបាល និងមូលនិធិគន្ធបុប្ផាកម្ពុជា ក៏ដូចជាប្រភពដទៃទៀត) ។ អង្គការអន្តរជាតិបម្រើសុខភាពប្រជាជន (Population Service International) បានប្រើប្រាស់ធនធានជាង ១៤ លានដុល្លារ ។ រីឯអង្គការសុខភាពគ្រួសារអន្តរជាតិ (Family

Health International ) បានប្រើប្រាស់ធនធាន ១៣ លានដុល្លារ ដែលភាគច្រើន ជាធនធានទទួលបានពីដៃគូអភិវឌ្ឍន៍ ។

### តារាងទី ២.៩ : ធនធានរបស់អង្គការមិនមែនរដ្ឋាភិបាលសំខាន់ៗ (លានដុល្លារ)

| ល.រ | ឈ្មោះអង្គការ | 2023 | | | 2024 | | | 2025 ប៉ាន់ស្មាន | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ធនធានផ្ទាល់ | ធនធានដៃគូ | សរុប | ធនធានផ្ទាល់ | ធនធានដៃគូ | សរុប | ធនធានផ្ទាល់ | ធនធានដៃគូ | សរុប |
| ១ | World Vision International | 22.2 | 4.8 | 27.0 | 25.4 | 4.7 | 30.2 | 28.0 | 2.6 | 30.6 |
| ២ | Foundation Children's Hospital Kantha Bopha | 26.7 | 4.4 | 31.1 | 25.1 | 3.9 | 28.9 | 31.8 | 3.9 | 35.6 |
| ៣ | Population Services International | 10.7 | 2.6 | 13.3 | 12.6 | 1.6 | 14.1 | 10.7 | 0.0 | 10.7 |
| ៤ | Family Health International | 0.0 | 14.4 | 14.4 | 0.0 | 13.0 | 13.0 | 0.1 | 0.1 | 0.2 |
| ៥ | Plan International | 5.4 | 6.3 | 11.7 | 6.1 | 6.7 | 12.8 | 4.7 | 2.4 | 7.0 |
| ៦ | Research Triangle Institute | 0.0 | 10.7 | 10.7 | 0.0 | 11.0 | 11.0 | 0.0 | 0.0 | 0.0 |
| ៧ | Wildlife Conservation Society | 5.5 | 2.4 | 8.0 | 7.3 | 2.4 | 9.7 | 7.6 | 0.8 | 8.4 |
| ៨ | Norwegian People's Aid | 2.5 | 5.5 | 8.0 | 2.3 | 7.0 | 9.3 | 2.3 | 2.9 | 5.1 |
| ៩ | Pour un Sourire 'Enfant | 8.3 | 0.0 | 8.3 | 8.6 | 0.0 | 8.6 | 8.5 | 0.0 | 8.5 |
| ១០ | Wildlife Alliance | 6.5 | 0.2 | 6.6 | 7.9 | 0.1 | 8.0 | 7.1 | 0.0 | 7.1 |
| ១១ | Cambodian Children's Fund | 7.9 | 0.0 | 7.9 | 7.8 | 0.0 | 7.8 | 5.7 | 0.0 | 5.7 |
| ១២ | Hazardous Area Life Support Organization Trust | 0.0 | 7.3 | 7.3 | 0.0 | 7.8 | 7.8 | 0.0 | 4.7 | 4.8 |

| ល.រ | ឈ្មោះអង្គការ | 2023 | | | 2024 | | | 2025 ប៉ាន់ស្មាន | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ធនធានផ្ទាល់ | ធនធានដៃគូ | សរុប | ធនធានផ្ទាល់ | ធនធានដៃគូ | សរុប | ធនធានផ្ទាល់ | ធនធានដៃគូ | សរុប |
| ១៣ | World Wide Fund for Nature - Cambodia | 2.2 | 2.0 | 4.2 | 3.4 | 2.7 | 6.1 | 2.2 | 2.2 | 4.4 |
| ១៤ | Mines Advisory Group | 2.0 | 3.8 | 5.8 | 1.3 | 4.6 | 6.0 | 1.0 | 1.3 | 2.3 |
| ១៥ | Khmer HIV/AIDS NGO Alliance | 0.0 | 3.6 | 3.6 | 0.0 | 5.7 | 5.7 | 0.0 | 0.0 | 0.0 |
| ១៦ | Room to Read | 4.3 | 0.0 | 4.3 | 5.5 | 0.0 | 5.5 | 3.8 | 0.0 | 3.8 |
| ១៧ | Conservation International Cambodia | 4.4 | 0.8 | 5.2 | 4.7 | 0.8 | 5.5 | 4.6 | 0.0 | 4.6 |
| ១៨ | Angkor Hospital for Children | 4.9 | 0.0 | 4.9 | 5.2 | 0.0 | 5.2 | 5.6 | 0.0 | 5.6 |
| ១៩ | The Asia Foundation | 1.4 | 3.8 | 5.1 | 1.3 | 3.9 | 5.2 | 0.9 | 3.2 | 4.1 |
| ២០ | Documentation Center of Cambodia | 0.0 | 2.4 | 2.4 | 0.0 | 5.1 | 5.1 | 0.0 | 0.0 | 0.0 |
| ២១ | Agape International Missions | 4.9 | 0.0 | 4.9 | 5.1 | 0.0 | 5.1 | 5.5 | 0.0 | 5.5 |
| ២២ | University Research Co., LLC | 0.0 | 4.9 | 4.9 | 0.0 | 4.9 | 4.9 | 0.0 | 0.0 | 0.0 |
| ២៣ | Save the Children International | 0.7 | 4.3 | 5.0 | 0.8 | 4.1 | 4.9 | 1.0 | 1.5 | 2.6 |
| ២៤ | Child Fund Cambodia | 4.5 | 0.2 | 4.7 | 4.4 | 0.2 | 4.6 | 3.0 | 0.3 | 3.2 |
| ២៥ | Clear Cambodia | 4.4 | 0.0 | 4.4 | 4.4 | 0.0 | 4.4 | 4.1 | 0.0 | 4.1 |
| ២៦ | Aide et Action, South-East Asia | 2.4 | 1.7 | 4.1 | 3.0 | 1.2 | 4.1 | 3.0 | 1.2 | 4.1 |
| ២៧ | Child's Dream Cambodia Organization | 2.9 | 0.0 | 2.9 | 4.0 | 0.0 | 4.0 | 3.4 | 1.0 | 4.5 |

| ល.រ | ឈ្មោះអង្គការ | 2023 | | | 2024 | | | 2025 ប៉ាន់ស្មាន | | |
|---|---|---|---|---|---|---|---|---|---|---|
| | | ធនធានផ្ទាល់ | ធនធានដៃគូ | សរុប | ធនធានផ្ទាល់ | ធនធានដៃគូ | សរុប | ធនធានផ្ទាល់ | ធនធានដៃគូ | សរុប |
| ២៨ | The Sonja Kill Foundation Cambodia | 3.8 | 0.0 | 3.8 | 4.0 | 0.0 | 4.0 | 3.7 | 0.0 | 3.7 |
| ២៩ | International Development Enterprises Cambodia | 0.2 | 2.3 | 2.5 | 0.3 | 3.6 | 3.9 | 1.8 | 0.5 | 2.3 |
| ៣០ | Samaritan's Purse International Relief | 2.9 | 0.0 | 2.9 | 3.9 | 0.0 | 3.9 | 3.7 | 0.0 | 3.7 |
| **អង្គការធំៗទាំង ៣០** | | 141.6 | 88.3 | 230.0 | 154.5 | 95.0 | 249.5 | 153.9 | 28.4 | 182.3 |
| **អង្គការ ៣១៣ ផ្សេងទៀត** | | 134.3 | 61.4 | 195.7 | 139.2 | 48.8 | 188.0 | 123.7 | 19.6 | 143.4 |
| សរុបរួម | | 275.9 | 149.7 | 425.7 | 293.7 | 143.8 | 437.5 | 277.6 | 48.1 | 325.7 |

# ជំពូក ៣
# ការពង្រឹងភាពជាដៃគូក្នុងកិច្ចអភិវឌ្ឍន៍

ដើម្បីគាំទ្រការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១, រាជ-រដ្ឋាភិបាលបានដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០២៤-២០២៨ និងសេចក្តីណែនាំស្តីពីយន្តការ និងឧបករណ៍សម្រាប់អនុវត្តយុទ្ធសាស្ត្រនេះ ក្នុងគោលដៅលើកកម្ពស់ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងពង្រឹងភាពជាដៃគូប្រកបដោយបរិយាប័ន្ន សំដៅរួមចំណែកសម្រេចបាននូវការអភិវឌ្ឍជាតិ និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ។

## ១. ការអង្កេតភាពជាដៃគូសកលលើកទី ៤ សម្រាប់ប្រសិទ្ធភាពនៃកិច្ចសហ-ប្រតិបត្តិការអភិវឌ្ឍន៍

រាជរដ្ឋាភិបាលបានប្តេជ្ញាបន្តអនុវត្តគោលការណ៍ស្តីពីស័ក្តិសិទ្ធភាពនៃកិច្ចអភិវឌ្ឍន៍ ដែលឯកភាពក្នុងកិច្ចប្រជុំកំពូលស្តីពីស័ក្តិសិទ្ធភាពនៃហិរញ្ញប្បទានសហប្រតិបត្តិការនាចុងឆ្នាំ២០១១ នៅទីក្រុងប៊ូសាន នៃសាធារណរដ្ឋកូរ៉េ ។ បន្ទាប់ពីទទួលបានជោគជ័យក្នុងការចូលរួមការធ្វើអង្កេតភាពជាដៃគូសកលចំនួន៣លើករួចមក, ក្នុងឆ្នាំ២០២៤នេះ ក.អ.ក ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជាដោយសហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល បានចូលរួមការធ្វើអង្កេតភាពជាដៃគូសកលលើកទី៤សម្រាប់ប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍។ ការធ្វើអង្កេតនេះបានប្រព្រឹត្តទៅជា ៥ ដំណាក់កាល គឺៈ ការប្រកាសចាប់ផ្តើមដំណើរការធ្វើអង្កេត, ការប្រមូលទិន្នន័យ, ការពិនិត្យផ្ទៀងផ្ទាត់, ការផ្សព្វផ្សាយលទ្ធផល និងការរៀបចំកិច្ចពិគ្រោះយោបល់ពហុភាគី ។

## តារាងទី ៣.១ ក្របខ័ណ្ឌលទ្ធផលស្តីពីស័ក្តិសិទ្ធភាពក្នុងកិច្ចអភិវឌ្ឍន៍

| សូចនាករ | 2016 | 2018 | 2025 |
|---|---|---|---|
| ១a- ការប្រើប្រាស់ក្របខ័ណ្ឌលទ្ធផលជាតិដោយដៃគូអភិវឌ្ឍន៍ | 85% | 55% | 60% |
| ១b- គុណភាពនៃផែនការអភិវឌ្ឍន៍ជាតិ និងក្របខ័ណ្ឌលទ្ធផលជាតិ | ការវាយតម្លៃបែបគុណវិស័យ | 84% | 81% |
| ២- បរិស្ថានអំណោយផលសម្រាប់សង្គមស៊ីវិល និងប្រសិទ្ធភាពក្នុងកិច្ចអភិវឌ្ឍន៍ | 100% | 59% | 63% |
| ៣- គុណភាពនៃកិច្ចពិគ្រោះយោបល់រវាងរដ្ឋ និងវិស័យឯកជន | 88% | 69% | - |
| ៤- ការផ្សព្វផ្សាយជាសាធារណៈនូវព័ត៌មាននៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ | - | 100% | 100% |
| ៥a- ការព្យាករណ៍ទំហំហិរញ្ញប្បទានសហប្រតិបត្តិការប្រចាំឆ្នាំ | 79% | 70% | 47% |
| ៥b- ការព្យាករណ៍ទំហំហិរញ្ញប្បទានសហប្រតិបត្តិការក្នុងរយៈពេលមធ្យម | 76% | 65% | 71% |
| ៦- ការតក់ត្រាហិរញ្ញប្បទានសហប្រតិបត្តិការក្នុងថវិការដ្ឋ | 79% | 78% | គ្មានទិន្នន័យ |
| ៧- គណនេយ្យភាពទ្វេទិសតាមរយៈការវាយតម្លៃប្រកបដោយបរិយាប័ន្ន | - | 3/5 | 1/5 |
| ៨- ប្រព័ន្ធតាមដានសមភាពយេនឌ័រ និងការពង្រឹងភាពអង់អាចរបស់ស្ត្រី | - | 1/3 | 2/3 |
| ៩a- គុណភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ជាតិ | - | គ្មានវឌ្ឍនភាពរួម | ប្រសើរឡើង |
| ៩b- ការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយដៃគូអភិវឌ្ឍន៍ | 48% | 62% | 58% |
| ១០- ហិរញ្ញប្បទានសហប្រតិបត្តិការឥតភ្ជាប់លក្ខខណ្ឌ | 87% | 91% | 78% |

*ប្រភព៖* ការធ្វើអង្កេតភាពជាដៃគូសកលសម្រាប់ប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍

លទ្ធផលនៃការធ្វើអង្កេតលើកទី៤បានបង្ហាញថា កម្ពុជាសម្រេចបានវឌ្ឍនភាពល្អស្មើរគ្រប់សូចនាករទាំងអស់ បើធៀបនឹងលទ្ធផលនៃការធ្វើអង្កេតលើកទី៣ នាឆ្នាំ២០១៨ ។ លទ្ធផលសំខាន់ៗរួមមាន៖

### *ក. សូចនាករស្តីពីការប្រើប្រាស់ក្របខ័ណ្ឌលទ្ធផលជាតិដោយដៃគូអភិវឌ្ឍន៍*

សូចនាករសម្រេចបានលទ្ធផលល្អប្រសើរ (៦០%) ដែលបានកើនឡើងធៀបនឹងឆ្នាំ២០១៨ (៥៥%) ដោយសារដៃគូអភិវឌ្ឍន៍ភាគច្រើនបានប្រើប្រាស់ក្របខ័ណ្ឌលទ្ធផលជាតិ សម្រាប់ជាមូលដ្ឋាននៅក្នុងការរៀបចំយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការរបស់ខ្លួន ។ ទន្ទឹមនឹងនេះដែរ, ដៃគូអភិវឌ្ឍន៍ក៏បានតម្រឹមគោលដៅ និងលទ្ធផលនៃគម្រោងថ្មីៗរបស់ខ្លួន ជាមួយក្របខ័ណ្ឌលទ្ធផលជាតិកាន់តែច្រើនឡើងក្នុងរង្វង់ ៩១% ។

### *ខ. សូចនាករស្តីពីគុណភាពនៃផែនការអភិវឌ្ឍន៍ជាតិ និងក្របខ័ណ្ឌលទ្ធផលជាតិ*

សូចនាករសម្រេចបានលទ្ធផលល្អក្នុងរង្វង់ ៨១% ទោះបីថយចុះបន្តិចធៀបនឹងឆ្នាំ២០១៨ (៨៤%) ដោយសារផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិសម្រាប់នីតិកាលទី៧នៃរដ្ឋសភាបានស្ថិតក្នុងដំណាក់កាលរៀបចំបញ្ចប់ ហើយមិនទាន់បានទទួលការអនុម័តពីស្ថាប័ននីតិប្បញ្ញត្តិ ក្នុងអំឡុងពេលនៃការធ្វើអង្កេតនេះ។ ទន្ទឹមនឹងនេះ រាជរដ្ឋាភិបាលបន្តសម្រេចបានវឌ្ឍនភាពក្នុងការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា ហើយបានរៀបចំក្របខ័ណ្ឌសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដោយកំណត់សូចនាករសមិទ្ធកម្មគន្លឹះ និងរៀបចំប្រព័ន្ធទិន្នន័យរឹងមាំ និងអាចជឿទុកចិត្តបាន ។

### *គ. សូចនាករស្តីពីបរិស្ថានអំណោយផលសម្រាប់សង្គមស៊ីវិល និងប្រសិទ្ធភាពក្នុងកិច្ចអភិវឌ្ឍន៍*

សូចនាករសម្រេចបាន ៦៣% ដែលបានកើនឡើងធៀបនឹងឆ្នាំ២០១៨ (៥៩%) ដោយសារក្រសួងមហាផ្ទៃដែលជាតំណាងរាជរដ្ឋាភិបាល រួមជាមួយដៃគូអភិវឌ្ឍន៍ ក៏ដូចជាអង្គការមិនមែនរដ្ឋាភិបាល បានវាយតម្លៃវិជ្ជមានអំពី

ការអនុវត្តច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល និងបានលើកកម្ពស់ការចូលរួមរបស់អង្គការសង្គមស៊ីវិលក្នុងកិច្ចអភិវឌ្ឍន៍ ។ លើសពីនេះ, អង្គការសង្គមស៊ីវិលក៏បានបញ្ជាក់អំពីកិច្ចខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការទទួលយកមតិយោបល់របស់អង្គការសង្គមស៊ីវិល សម្រាប់ជាមូលដ្ឋានក្នុងការរៀបចំគោលនយោបាយស្តីពីកិច្ចអភិវឌ្ឍន៍ជាតិ ។

### *ឃ. សូចនាករស្តីពីការព្យាករណ៍ទំហំហិរញ្ញប្បទានសហប្រតិបត្តិការក្នុងរយៈពេលមធ្យម*

សូចនាករសម្រេចបាន ៧១% ដែលបានកើនឡើងធៀបនឹងឆ្នាំ២០១៨ (៦៥%) ដោយសាររាជរដ្ឋាភិបាលមានប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ ហើយដោយបានសហការជាមួយដៃគូអភិវឌ្ឍន៍ ក៏ដូចជាភាគីពាក់ព័ន្ធ បានកត់ត្រាជាប្រចាំនូវលំហូរការបើកផ្តល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ទាំងអស់ និងការព្យាករណ៍ការបើកផ្តល់ហិរញ្ញប្បទានទាំងនេះសម្រាប់រយៈពេលមធ្យមផងដែរ ។

### *ង. សូចនាករស្តីពីគណនេយ្យភាពទ្វេទិស តាមរយៈការវាយតម្លៃប្រកបដោយបរិយាប័ន្ន*

សូចនាករទទួលបានពិន្ទុ ១/៥ ដែលបានថយចុះធៀបនឹងឆ្នាំ២០១៨ (៣/៥) ដោយសារការផ្លាស់ប្តូរវិធីសាស្ត្រគណនា។ ទោះជាយ៉ាងនេះក្តី លទ្ធផលក៏បានបង្ហាញថា ការប្រើប្រាស់នូវក្របខ័ណ្ឌគោលនយោបាយស្តីពីកិច្ចសហ-ប្រតិបត្តិការអភិវឌ្ឍន៍គ្រប់ជ្រុងជ្រោយ ដែលជាផ្នែកសំខាន់នៃសូចនាករនេះមានវឌ្ឍនភាពល្អប្រសើរ ដោយសាររាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០២៤-២០២៨ និង

សេចក្តីណែនាំស្តីពីការអនុវត្តនូវយន្តការ និងឧបករណ៍សម្រាប់លើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ។

### *ច. សូចនាករស្តីពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដោយដៃគូអភិវឌ្ឍន៍*

សូចនាករសម្រេចបាន ៥៨% ដែលថយចុះបន្តិចធៀបនឹងឆ្នាំ២០១៨ (៦២%) ម្យ៉ាង ដោយសារមានស្ថាប័នរបស់ភ្នាក់ងារនៃប្រព័ន្ធអង្គការសហ-ប្រជាជាតិជាច្រើនបានប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុផ្ទាល់ខ្លួន និងម្យ៉ាងទៀតដោយសារដៃគូអភិវឌ្ឍន៍ ដែលផ្តល់ហិរញ្ញប្បទានធំមិនបានចូលរួមក្នុងការអង្កេតលើកនេះ ។

## ២. វឌ្ឍនភាពក្នុងការអនុវត្តយន្តការភាពជាដៃគូ

ក្នុងឆ្នាំ២០២៤ កិច្ចពិគ្រោះយោបល់ កិច្ចពិភាក្សាកម្រិតគោលនយោបាយ ឬការចរចាទ្វេភាគីសំខាន់ៗជាមួយដៃគូអភិវឌ្ឍន៍ត្រូវបានរៀបចំឡើង ដូចជាកិច្ចពិគ្រោះយោបល់កម្រិតខ្ពស់បំផុតរវាង **សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី** ជាមួយនឹងប្រព័ន្ធអង្គការសហប្រជាជាតិ, កិច្ចប្រជុំពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីប្រចាំប្រទេសរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំកម្ពុជា, កិច្ចប្រជុំត្រួតពិនិត្យវឌ្ឍនភាពនៃការអនុវត្តកម្មវិធីអភិវឌ្ឍន៍ប្រចាំប្រទេសរបស់កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំកម្ពុជានិងមូលនិធិសហប្រជាជាតិសម្រាប់ប្រជាជនប្រចាំកម្ពុជា, កិច្ចពិភាក្សាកម្រិតគោលនយោបាយលើកទី៥រវាងរាជរដ្ឋាភិបាល និងសាធារណរដ្ឋកូរ៉េ, កិច្ចពិគ្រោះយោបល់ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍រវាងរាជរដ្ឋាភិបាល និងសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់, កិច្ចប្រជុំគណៈកម្មាធិការចម្រុះរវាងរាជរដ្ឋាភិបាល និងសហភាពអឺរ៉ុបជាដើម ។

## ៣. លទ្ធផលនៃការពិនិត្យសមិទ្ធកម្មរបស់ក្រុមការងារបច្ចេកទេសចម្រុះ

ក្នុងត្រីមាសទី២ ឆ្នាំ២០២៥, ក.អ.ក បានធ្វើអង្កេតខ្លីមួយ ដើម្បីវាយតម្លៃលើសមិទ្ធកម្មរបស់ក្រុមការងារបច្ចេកទេសចម្រុះក្នុងឆ្នាំ២០២៤ ។ ក្រុមការងារបច្ចេកទេសចម្រុះចំនួន ១៨ ក្នុងចំណោម ២០ បានឆ្លើយទៅនឹងកម្រងសំណួរអង្កេតនេះ ។ លទ្ធផលបានបង្ហាញថា យន្តការក្រុមការងារចម្រុះបានដំណើរការល្អគួរឱ្យកត់សម្គាល់ ។ ក្រុមការងារចំនួន ១៣ (៦៥%) បានដំណើរការផ្អែកតាមលក្ខខណ្ឌយោងច្បាស់លាស់ ខណៈដែលក្រុមការងារចំនួន ៣ (១៥%) កំពុងរៀបចំ និងក្រុមការងារចំនួន ២ (១០%) ពុំមានលក្ខខណ្ឌយោង ដោយបានលើកបង្ហាញមូលហេតុច្បាស់លាស់ ។ ក្រុមការងារចំនួន ៥ មានវឌ្ឍនភាពល្អប្រសើរក្នុងការអនុវត្តផែនការសកម្មភាពក្នុងរង្វង់ ៩០%-១០០% ខណៈដែលក្រុមការងារចំនួន ៥ ទៀតមានវឌ្ឍនភាពល្អ (៧៦%-៨៩%) ហើយក្រុមការងារចំនួន ៣ មានវឌ្ឍនភាពល្អបង្គួរ (៦៦%-៧៥%) និងក្រុមការងារចំនួន ១ មានវឌ្ឍនភាពមធ្យម (៥០%-៦៥%) ។ រីឯក្រុមការងារចំនួន ៤ ទៀតពុំបានផ្តល់របាយការណ៍ស្តីពីវឌ្ឍនភាពឡើយ ។ លើសពីនេះ, ក្រុមការងារភាគច្រើនបានលើកឡើងថា ការចូលរួមពីតួអង្គពាក់ព័ន្ធមានភាពសកម្ម និងបរិយាប័ន្ន ។ ចំពោះការរៀបចំកិច្ចប្រជុំវិញ, ក្រុមការងារចំនួន ៤ បានរៀបចំកិច្ចប្រជុំលើសពី ៣ ដង ទន្ទឹមនឹងក្រុមការងារចំនួន ៤ បានរៀបចំកិច្ចប្រជុំចំនួន ២ ដង ហើយក្រុមការងារចំនួន ៤ ទៀតមិនទាន់រៀបចំកិច្ចប្រជុំម្តងឡើយ ។

ក្រុមការងារបច្ចេកទេសចម្រុះភាគច្រើនបានលើកឡើងពីបញ្ហាប្រឈមដែលរួមមាន៖ កង្វះខាតថវិកា និងជំនាញបច្ចេកទេសក្នុងការអនុវត្តផែនការសកម្មភាព, សមត្ថភាពមន្ត្រីនៅមានកម្រិត ហើយមិនទាន់ឆ្លើយតបនឹងតម្រូវការការងារជាក់ស្តែង និងការថមថយនៃហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍ផងដែរ ។ លើមូលដ្ឋាននេះ, ក្រុមការងារភាគច្រើនបានលើកអំពីតម្រូវការក្នុងការកៀរគរ

ថវិកាសម្រាប់គាំទ្រដល់កិច្ចដំណើរការរបស់ក្រុមការងារ, ការរៀបចំកិច្ចប្រជុំឱ្យបានទៀងទាត់, ការពង្រឹងកិច្ចសម្របសម្រួលកិច្ចការអន្តរវិស័យសម្រាប់ចូលរួម និងដោះស្រាយបញ្ហាប្រឈម ទន្ទឹមនឹងការពង្រឹងសមត្ថភាពមន្ត្រី និងស្ថាប័ន ។

# ជំពូក ៤
# ការលើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការសម្រាប់គាំទ្រដល់ការអនុវត្តគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា

គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (គ.អ.ច.ក) ត្រូវបានធ្វើសមាហរណកម្មទៅក្នុងក្របខ័ណ្ឌគោលនយោបាយជាតិសំខាន់ៗ ដូចជា យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់ទី១, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដើម្បីធានាបានសង្គតិភាពរវាងឯកសារយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ។ គ.អ.ច.ក ក៏ជាឯកសារមូលដ្ឋានសំខាន់ សម្រាប់រៀបចំផែនការ វិភាជន៍ថវិកា និងសម្រាប់ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយផងដែរ ។

រាជរដ្ឋាភិបាលបាន និងបន្តកៀរគរហិរញ្ញប្បទានពីគ្រប់តួអង្គអភិវឌ្ឍន៍ ដើម្បីគាំទ្រដល់ការអនុវត្តគោលដៅទាំង១៨ នៃ គ.អ.ច.ក.។ ការគាំទ្រធនធានតាមគោលដៅនីមួយៗ ត្រូវបានកត់ត្រាក្នុងប្រព័ន្ធទិន្នន័យកម្ពុជាស្តីពីហិរញ្ញប្បទានសហប្រតិបត្តិការ ដែលគ្រប់គ្រងដោយ គ.ស.អ.ក/ក.អ.ក ។ តារាងទី ៤.១ បានបង្ហាញពីហិរញ្ញប្បទានដែលបានគាំទ្រដល់គោលដៅទាំង១៨ នៃ គ.អ.ច.ក ចាប់ពីឆ្នាំ២០២២ ដល់ឆ្នាំ២០២៥ ។ គួរកត់សម្គាល់ដែរថា, គោលដៅទី៩ ស្តីពី "ឧស្សាហកម្ម, នវានុវត្តន៍ និងហេដ្ឋារចនាសម្ព័ន្ធ" ទទួលការគាំទ្រច្រើនជាងគេ ជាមធ្យម ២៨% នៃហិរញ្ញប្បទានសរុបដែលគាំទ្រ គ.អ.ច.ក ។ រីឯគោលដៅទី៣ ស្តីពី "សុខភាពល្អ និងសុខុមាលភាព" ទទួលបានការគាំទ្រច្រើនលំដាប់ទី២ ស្មើនឹង ១៤% ។ ចំពោះគោលដៅទី១៥ ស្តីពី "ជីវិតរស់នៅលើផែនដី" គឺជាគោលដៅដែលទទួលបានការគាំទ្រតិចជាងគេ ។

## តារាងទី ៤.១ : ការបើកផ្តល់ហិរញ្ញប្បទានតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា

| គោលដៅ | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (លានដុល្លារ) | ២០២២ | ២០២៣ | ២០២៤ | ២០២៥ ប៉ាន់ស្មាន | % ធៀបនឹងសរុប |
|---|---|---|---|---|---|---|
| ១ | បញ្ចប់ភាពក្រីក្រគ្រប់ទម្រង់ និងគ្រប់ទីកន្លែង | 84.5 | 55.9 | 62.3 | 74 | 4% |
| ២ | បញ្ចប់ភាពអត់ឃ្លាន សម្រេចបានសន្តិសុខស្បៀង ធ្វើឱ្យប្រសើរឡើងស្ថានភាពអាហារូបត្ថម្ភ និងលើកកម្ពស់កសិកម្មប្រកបដោយចីរភាព | 105.3 | 91.1 | 111.7 | 102.6 | 6% |
| ៣ | ធានាជីវភាពរស់នៅរបស់ប្រជាជនប្រកបដោយសុខភាពល្អ និងលើកកម្ពស់សុខុមាលភាពរបស់មនុស្សគ្រប់រូប និងគ្រប់វ័យ | 314.8 | 190.5 | 205.6 | 330.3 | 14% |
| ៤ | ធានាការអប់រំប្រកបដោយគុណភាព បរិយាប័ន្ន និងសមធម៌ និងលើកកម្ពស់កាលានុវត្តភាពសិក្សាពេញមួយជីវិតសម្រាប់ប្រជាជនគ្រប់រូប | 115 | 115.4 | 112.7 | 94.9 | 6% |
| ៥ | សម្រេចឱ្យបានសមភាពយេនឌ័រ និងពង្រឹកភាពអង់អាចរបស់ស្ត្រី និងកុមារីគ្រប់រូប | 85.2 | 48.6 | 106.9 | 81.1 | 4% |
| ៦ | ធានាការទទួលបានទឹក និងអនាម័យ និងគ្រប់គ្រងទឹកអនាម័យប្រកបដោយចីរភាពសម្រាប់ប្រជាជនគ្រប់រូប | 90.1 | 140.1 | 190 | 167.9 | 8% |
| ៧ | ធានាការទទួលបានថាមពលដែលមានបច្ចេកទេសទំនើបប្រកបដោយចីរភាព អាចជឿជាក់បាន និងមានតម្លៃសមរម្យសម្រាប់ប្រជាជនគ្រប់រូប | 40.6 | 62.6 | 72.9 | 74.8 | 3% |
| ៨ | ជំរុញកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងបរិយាប័ន្ន មានមុខរបរពេញលេញ និងផលិតភាព និងមានការងារសមរម្យសម្រាប់ប្រជាជនគ្រប់រូប | 120.6 | 213 | 166.2 | 167.2 | 9% |

| គោលដៅ | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា (លានដុល្លារ) | ២០២២ | ២០២៣ | ២០២៤ | ២០២៥ ប៉ាន់ស្មាន | % ធៀប នឹងសរុប |
|---|---|---|---|---|---|---|
| ៩ | កសាងហេដ្ឋារចនាសម្ព័ន្ធធន់នឹងការប្រែប្រួលអាកាសធាតុ ជំរុញឧស្សាហូបនីយកម្មប្រកបដោយចីរភាព និងបរិយាប័ន្ន និងលើកកម្ពស់នវានុវត្តន៍ | 547 | 598 | 493 | 398.9 | 28% |
| ១០ | កាត់បន្ថយវិសមភាពក្នុងប្រទេស និងរវាងប្រទេស | 45.2 | 18.7 | 29.6 | 15.6 | 2% |
| ១១ | ទីក្រុង និងកន្លែងតាំងទីលំនៅថ្មីសម្រាប់ប្រជាជន មានលក្ខណៈបរិយាប័ន្ន សុវត្ថិភាព ធន់នឹងការប្រែប្រួលអាកាសធាតុ និងចីរភាព | 42.3 | 46.4 | 55.5 | 88 | 3% |
| ១២ | ធានាចីរភាពក្នុងទម្រង់នៃការប្រើប្រាស់ និងផលិតកម្ម | 7 | 17.2 | 5.9 | 5 | 0.5% |
| ១៣ | ចាត់វិធានការបន្ទាន់ ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់ | 115 | 111.9 | 184.7 | 148.5 | 8% |
| ១៤ | អភិរក្ស និងប្រើប្រាស់ប្រកបដោយចីរភាពនូវមហាសមុទ្រ សមុទ្រ និងធនធានសមុទ្រ សម្រាប់ការអភិវឌ្ឍប្រកប ដោយចីរភាព | 4.4 | 14.7 | 4.8 | 12.5 | 0.5% |
| ១៥ | ការពារ ស្តារ និងជំរុញការប្រើប្រាស់ប្រកបដោយ ចីរភាព នូវប្រព័ន្ធអេកូឡូស៊ីក្នុងការគ្រប់គ្រង ព្រៃឈើប្រកបដោយចីរភាព ប្រយុទ្ធប្រឆាំងនឹង ឱនភាពដី បញ្ឈប់ និងបង្វែរទិសនៃការសឹក រេចរឹលគុណភាពដី និងកាត់បន្ថយការបាត់បង់ជីជាតិដី និងជីវៈចម្រុះ | 8.7 | 4.9 | 2.2 | 1.3 | 0.2% |
| ១៦ | លើកកម្ពស់សង្គមដែលមានសន្តិភាពប្រកបដោយបរិយាប័ន្ន សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព ផ្តល់នូវការទទួលបាន | 35 | 41.3 | 37.8 | 23.7 | 2% |

| | | | | | | |
|---|---|---|---|---|---|---|
| | យុត្តិធម៌សម្រាប់ប្រជាជន គ្រប់រូប និងកសាងស្ថាប័ន ដែលមានប្រសិទ្ធភាព គណនេយ្យ និងបរិយាប័ន្ននៅគ្រប់កម្រិត | | | | | |
| ១៧ | ពង្រឹងមធ្យោបាយអនុវត្តនានា និងបង្កើតភាព រស់រវើកនៃភាពជាដៃគូសកលសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព | 7.5 | 7.3 | 7 | 7 | 0.4% |
| ១៨ | បញ្ចប់ផលប៉ះពាល់អវិជ្ជមានរបស់មីន/សំណល់ជាតិផ្ទុះពីសង្គ្រាម និងជំរុញការសង្គ្រោះជនរងគ្រោះ | 31.1 | 25.1 | 22.7 | 17.4 | 1% |
| សរុប | | 1,799.4 | 1,802.6 | 1,871.6 | 1,810.6 | 100% |

តារាងទី ៤.២ បានបង្ហាញថា ក្នុងឆ្នាំ២០២៣, ធនាគារអភិវឌ្ឍន៍អាស៊ីបានបើកផ្តល់ហិរញ្ញប្បទានច្រើនជាងគេ ប្រមាណជាង ៣៩៤ លានដុល្លារ ស្មើនឹង ២២% នៃហិរញ្ញប្បទានសរុប ។ បន្ទាប់មកគឺសាធារណរដ្ឋប្រជាមានិតចិន (៣៨៦លានដុល្លារ ស្មើនឹង ២១%) និងជប៉ុន (២៨៥ លានដុល្លារ ឬ១៦%)។ ធនាគារអភិវឌ្ឍន៍អាស៊ីបានបើកផ្តល់ហិរញ្ញប្បទានច្រើនជាងគេសម្រាប់គាំទ្រការអនុវត្តគោលដៅទី៨ ស្តីពី "ការធានាកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងការងារសមរម្យ" ក្នុងទំហំជាង ១២១ លានដុល្លារ និងគោលដៅទី១៣ ស្តីពី "ការអភិរក្សបរិស្ថាន" ក្នុងទំហំជិត ៦៩ លានដុល្លារ ដើម្បីរួមចំណែកដល់កំណើនសេដ្ឋកិច្ច និងប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ ។ សាធារណរដ្ឋប្រជាមានិតចិនបានបើកផ្តល់ហិរញ្ញប្បទានដល់គោលដៅទី៩ ស្តីពី "ឧស្សាហកម្មនវានុវត្តន៍ និងហេដ្ឋារចនាសម្ព័ន្ធ" ក្នុងទំហំជិត ៣០៣ លានដុល្លារ និងគោលដៅទី៦ ស្តីពី "ទឹកស្អាត និងអនាម័យ" ២៥ លានដុល្លារ ។ ជប៉ុនបានបើកផ្តល់ហិរញ្ញប្បទានច្រើនសម្រាប់គោលដៅទី៩ ក្នុងទំហំ ១៦១ លានដុល្លារ និងគោលដៅទី៦ ៥១ លានដុល្លារ ។ រីឯដៃគូអភិវឌ្ឍន៍ដទៃទៀតបានផ្តល់ធនធាន

ជាង ១២៧ លានដុល្លារ ស្មើនឹង ៦% នៃហិរញ្ញប្បទានសរុប ដោយបានផ្ដោតការគាំទ្រភាគច្រើនលើគោលដៅទី៣ ស្ដីពី "សុខភាពល្អ និងសុខុមាលភាព" ក្នុងទំហំជិត ៥៣ លានដុល្លារ ដែលបានចូលរួមចំណែកសំខាន់ដល់ការជួយពង្រឹងវិស័យសុខាភិបាល ។

**តារាងទី ៤.២ : ការបើកផ្ដល់ហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍន៍សំខាន់ៗ តាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ឆ្នាំ២០២៣**

| គោលដៅ | ដៃគូអភិវឌ្ឍន៍ (លានដុល្លារ) | | | | | | | | | | | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ADB | China | Japan | UN | World Bank | USA | South Korea | Fra-nce | Aus-tralia | EU/ EC | Other | |
| គ.១ | 11.8 | - | 0.8 | 9.4 | 1.6 | 9.4 | 6.6 | 1.4 | 0.3 | 6.4 | 8.1 | 55.9 |
| គ.២ | 26.1 | 19.2 | 9.1 | 6.9 | 2.7 | 9.2 | 7.1 | 2.5 | 2.3 | 0.1 | 6.0 | 91.1 |
| គ.៣ | 30.4 | 4.4 | 12.1 | 16.2 | 19.6 | 28.2 | 13.4 | 3.2 | 10.3 | 0.0 | 52.8 | 190.6 |
| គ.៤ | 9.9 | - | 5.9 | 9.6 | 51.9 | 9.8 | 10.5 | 1.1 | 6.3 | 3.5 | 7.0 | 115.4 |
| គ.៥ | 10.2 | - | 1.4 | 6.9 | - | 12.0 | 1.0 | 0.8 | 4.0 | 1.8 | 10.6 | 48.6 |
| គ.៦ | 30.4 | 25.1 | 50.8 | 3.5 | 4.0 | 6.1 | 0.9 | 10.6 | 6.2 | 2.0 | 0.6 | 140.1 |
| គ.៧ | 25.7 | 14.0 | 20.9 | 1.0 | - | 0.4 | 0.2 | 0.0 | 0.1 | - | 0.3 | 62.6 |
| គ.៨ | 121.4 | 16.5 | 0.5 | 8.6 | 2.8 | 13.7 | 16.7 | 7.2 | 7.0 | 8.7 | 10.0 | 213.0 |
| គ.៩ | 34.3 | 302.5 | 160.6 | 0.9 | 69.8 | 0.1 | 22.6 | 0.2 | 1.6 | 0.2 | 5.3 | 598.0 |
| គ.១០ | 2.1 | - | 0.3 | 2.5 | 0.8 | 2.6 | - | 4.4 | 2.4 | 2.1 | 1.6 | 18.7 |
| គ.១១ | 22.8 | - | 11.1 | 1.3 | - | 1.1 | 6.9 | 0.8 | 0.4 | 0.1 | 1.9 | 46.4 |
| គ.១២ | - | - | - | 0.8 | - | 4.0 | - | 10.2 | 1.7 | - | 0.4 | 17.2 |
| គ.១៣ | 68.8 | - | 0.4 | 5.7 | 2.7 | 7.8 | 9.0 | 4.1 | 0.4 | 4.5 | 8.4 | 111.9 |
| គ.១៤ | - | - | 0.0 | 0.1 | - | 0.4 | - | 1.5 | - | 12.3 | 0.5 | 14.7 |
| គ.១៥ | - | - | 0.1 | 0.4 | - | 2.2 | - | - | 0.6 | 0.1 | 1.7 | 4.9 |
| គ.១៦ | 0.1 | - | 9.1 | 4.0 | - | 10.5 | 1.7 | 0.4 | 3.7 | 3.1 | 8.6 | 41.3 |
| គ.១៧ | 0.4 | - | 0.1 | 2.6 | 1.2 | 1.3 | - | 0.3 | - | 1.4 | 0.0 | 7.3 |
| គ.១៨ | - | 4.4 | 1.7 | - | - | 12.0 | 0.9 | - | 1.4 | - | 4.7 | 25.1 |
| **សរុប** | **394.4** | **386.1** | **284.7** | **80.5** | **157.0** | **130.7** | **97.5** | **48.6** | **48.6** | **46.3** | **128.3** | **1,802.6** |
| **% ធៀបការផ្ដល់សរុប** | **22%** | **21%** | **16%** | **4%** | **9%** | **7%** | **5%** | **3%** | **3%** | **3%** | **7%** | **100%** |

# ជំពូក ៥
# សេចក្តីសន្និដ្ឋាន

រាជរដ្ឋាភិបាលសម្រេចបានសមិទ្ធផលសំខាន់ៗនៅក្នុងការកៀរគរ និងគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ និងការពង្រឹងភាពជាដៃគូប្រកបដោយស័ក្តសិទ្ធភាព និងបរិយាប័ន្ន ដើម្បីសម្រេចបានការចាកចេញពីប្រទេសអភិវឌ្ឍន៍តិចតួចនាឆ្នាំ២០២៩ ក៏ដូចជាសម្រេចបានឋានៈជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ។ របាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ឆ្នាំ២០២៥នេះ បានវិភាគគ្រប់ជ្រុងជ្រោយលើគ្រប់ទិដ្ឋភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងអាទិភាពដែលមានចែងក្នុងយុទ្ធសាស្ត្រស្តីពីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងភាពជាដៃគូ ២០២៤-២០២៨ ។ ទន្ទឹមនឹងនេះ, របាយការណ៍នេះបានឆ្លុះបញ្ចាំងអំពីការវិវត្តទូទៅនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍នៅកម្ពុជា និងបានផ្តល់សក្ខីកម្មជាក់លាក់ ដែលបង្ហាញអំពីសមត្ថភាពរបស់រាជរដ្ឋាភិបាលនៅក្នុងការកៀរគរ សម្របសម្រួល និងគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងបរិយាប័ន្ន ។

របាយការណ៍បានបង្ហាញថា ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការរក្សាបាននូវលំនឹងជាមធ្យមប្រមាណ ២.១០០ លានដុល្លារក្នុងមួយឆ្នាំ ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ ២០២១-២០២៥ ដែលបង្ហាញពីភាពជាម្ចាស់និងសមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការកៀរគរ និងគ្រប់គ្រងហិរញ្ញប្បទានក៏ដូចជាការបន្តពង្រឹងភាពជាដៃគូជាមួយតួអង្គអភិវឌ្ឍន៍ ។ ទំហំហិរញ្ញប្បទានដែលបានបើកផ្តល់ក្នុងឆ្នាំ២០២៣ មានជាង ២.១០០ លានដុល្លារ និងបានកើនដល់ជិត ២.២០០ លានដុល្លារ ក្នុងឆ្នាំ២០២៤ ហើយត្រូវបានព្យាករណ៍ថាអាចសម្រេចបានក្នុងទំហំប្រមាណ ២.១០០ លានដុល្លារ ក្នុងឆ្នាំ២០២៥, ក្នុងនោះហិរញ្ញប្បទានឥតសំណងមាន ៤០% ខណៈដែលឥណទានសម្បទាន

បានកើនរហូតដល់ ៦០% នៃហិរញ្ញប្បទានសរុប ក្នុងឆ្នាំ២០២៤ និងអាចបន្តកើនដល់ ៦៤% ក្នុងឆ្នាំ២០២៥ ។ ការណ៍នេះបញ្ជាក់ពីការប្រែប្រួលបរិបទដែលកម្ពុជាកំពុងឈានចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច ។ អនុបាតហិរញ្ញប្បទានធៀបនឹង ផ.ស.ស រក្សាទំហំថេរក្នុងរង្វង់ ៥% ក្នុងឆ្នាំ២០២១-២០២៥ ។ ទន្ទឹមនឹងនេះ, ការបើកផ្តល់ហិរញ្ញប្បទានតាមវិស័យបានបង្ហាញថាដៃគូអភិវឌ្ឍន៍នៅតែផ្តល់អាទិភាពទៅក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធ, សេដ្ឋកិច្ច និងសង្គមកិច្ច ដែលជាវិស័យអាទិភាពខ្ពស់នៅក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១។

ដៃគូអភិវឌ្ឍន៍ដែលបន្តឈានមុខក្នុងការបើកផ្តល់ហិរញ្ញប្បទានរួមមាន៖ សាធារណរដ្ឋប្រជាមានិតចិន, ជប៉ុន, សាធារណរដ្ឋកូរ៉េ, ធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក ។ ហិរញ្ញប្បទានទាំងអស់របស់បណ្តាដៃគូអភិវឌ្ឍន៍នៅតែបន្តតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និងជាកាតាលីករសម្រាប់កៀគរធនធានពីប្រភពដទៃ ពិសេសពីវិស័យឯកជន ដើម្បីជំរុញកិច្ចអភិវឌ្ឍន៍ជាតិឈានទៅសម្រេចចក្ខុវិស័យឆ្នាំ២០៥០។ លើសពីនេះ, ក៏បង្ហាញការជឿទុកចិត្តពីសំណាក់ដៃគូអភិវឌ្ឍន៍មកលើភាពដឹកនាំ និងភាពជាម្ចាស់របស់រាជរដ្ឋាភិបាលក្នុងកិច្ចប្រឹងប្រែងកៀគរធនធានក្នុងស្រុក ក៏ដូចជាសមត្ថភាពក្នុងការគ្រប់គ្រងឥណទានសម្បទាន និងបំណុល ។

ដូចធ្លាប់បានអនុវត្តកន្លងមក រាជរដ្ឋាភិបាលបានដឹកនាំការអង្កេតភាពជាដៃគូសកលលើកទី៤សម្រាប់ប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ដោយមានការចូលរួមពីស្ទើរគ្រប់តួអង្គអភិវឌ្ឍន៍ទាំងអស់។ ជាលទ្ធផល កម្ពុជាសម្រេចបានវឌ្ឍនភាពស្ទើរគ្រប់សូចនាករសំខាន់ៗ ដូចជាការប្រើប្រាស់នូវក្របខ័ណ្ឌលទ្ធផលជាតិ, ការព្យាករណ៍ហិរញ្ញប្បទានរយៈពេលមធ្យម និងភាពជាដៃគូប្រកបដោយបរិយាប័ន្ន។ ទន្ទឹមនឹងនេះ, ក៏មានសូចនាករមួយចំនួនមានលទ្ធផល

ថយចុះបន្តិច ដោយសារការប្រើប្រាស់វិធីសាស្ត្រថ្មីក្នុងការគណនា ។ ទោះជាយ៉ាងនេះក្តី, ក៏លទ្ធផលនៃការអង្កេតលើកទី៤នេះមានភាពល្អប្រសើរ ធៀបនឹងការអង្កេតលើកទី៣ កាលពីឆ្នាំ២០១៨ ។ រីឯយន្តការភាពជាដៃគូដទៃទៀត ដូចជាកិច្ចពិគ្រោះយោបល់ និងកិច្ចប្រជុំរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាល ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ បាននិងកំពុងដំណើរការជាប្រក្រតី ក្រោមការដឹកនាំនិងសម្របសម្រួលរបស់ក្រសួង និងស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ។ ចំពោះកិច្ចដំណើរការរបស់ក្រុមការងារបច្ចេកទេសចម្រុះវិញ, មានក្រុមការងារចំនួន ១៣ (៦៥%) មានលក្ខខណ្ឌយោងច្បាស់លាស់ និងបានប្រជុំយ៉ាងទៀងទាត់ ដោយមានការចូលរួមយ៉ាងសកម្មពីតួអង្គពាក់ព័ន្ធទាំងអស់ ។

ទន្ទឹមនឹងនេះ ការបើកផ្តល់ហិរញ្ញប្បទានសម្រាប់គាំទ្រ គ.អ.ច.ក ត្រូវបានធ្វើឡើងយ៉ាងសកម្ម និងមានវឌ្ឍនភាពល្អប្រសើរ ដោយមានការចូលរួមពីគ្រប់តួអង្គអភិវឌ្ឍន៍ជាច្រើន ។ ក្នុងការអនុវត្តគោលដៅទាំង១៨ នៃ គ.អ.ច.ក, គោលដៅទី៩ ស្តីពី "ឧស្សាហកម្ម, នវានុវត្តន៍ និងហេដ្ឋារចនាសម្ព័ន្ធ" ទទួលបានហិរញ្ញប្បទានច្រើនជាងគេ ប្រមាណ ២៨% នៃហិរញ្ញប្បទានសរុបដែលគាំទ្រ គ.អ.ច.ក ។ រីឯគោលដៅទី៣ ស្តីពី "សុខភាពល្អ និងសុខុមាលភាព" ទទួលបានហិរញ្ញប្បទានច្រើនលំដាប់ទី២ ស្មើនឹង ១៤% ក្នុងពេលដែល គោលដៅទី១៥ ស្តីពី "ជីវិតរស់នៅលើផែនដី" ទទួលបានការគាំទ្រតិចជាងគេ ។

ផ្អែកលើរបកគំហើញក្នុងរបាយការណ៍, ហិរញ្ញប្បទានសហប្រតិបត្តិការនៅតែបន្តតួនាទីសំខាន់នៅក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេលមធ្យមខាងមុខ។ លើមូលដ្ឋាននេះ រាជរដ្ឋាភិបាលនឹងបន្តខិតខំគ្រប់គ្រងការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវធនធានទាំងនេះ និងលើកទឹកចិត្តឱ្យប្រើប្រាស់ទម្រង់ថ្មីៗផ្សេងទៀត ដើម្បីកៀរគរហិរញ្ញប្បទានបន្ថែម ទាំងពីវិស័យសាធារណៈ

និងឯកជន សម្រាប់បំពេញឱ្យធនធានក្នុងស្រុក ដើម្បីរួមចំណែកសម្រេចឱ្យបាននូវគោលដៅអភិវឌ្ឍន៍ជាតិ ។ ក្នុងស្មារតីនេះ, រាជរដ្ឋាភិបាលបានប្តេជ្ញាខ្ពស់ក្នុងការបន្តដឹកនាំជំរុញ និងពង្រឹងការអនុវត្តយន្តការភាពជាដៃគូជាមួយគ្រប់តួអង្គអភិវឌ្ឍន៍ ដើម្បីកៀរគរ តម្រឹម និងគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការប្រកបដោយបរិយាប័ន្ន សំដៅលើកកម្ពស់ស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ ៕

## ការបើកផ្តល់ហិរញ្ញប្បទានសហប្រតិបត្តិការតាមដៃគូអភិវឌ្ឍន៍ និងតាមវិស័យ ឆ្នាំ២០២២ (លានដុល្លារ)

| Development Partners | Term of Assistance | Health | Education | Social Protection | Agriculture | Manufacturing, Mining & Trade | Rural Development | Bank. & Biz | Urban Plan & Management | Information & Communications | Energy, Power & Electricity | Transportation | Water & sanitation | Comm. & Social | Culture & Arts | Enviro. & Conserv. | Climate Change | Gender | HID/ AIDS | Governance & Administration | Tourism | Budget & BoP Support | Emergency & Food Aid | Others | Total |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| UN Own Funds | Grant | 13 | 16 | 4 | 4 | 1 | 5 | 0 | | 1 | 1 | | 0 | 10 | 0 | 3 | 2 | 1 | 1 | 3 | 1 | 0 | 2 | 5 | 71 |
| | Loan | | | | 13 | | 24 | | | | | | | | | | | | | | | | | | 37 |
| World Bank | Grant | | 1 | | | | | | | | | | | | | 1 | | | | | | | | | 1 |
| | Loan | 32 | 9 | | 24 | | 29 | | | | | 14 | 1 | | | 1 | | | | | | | | 200 | 311 |
| ADB | Grant | 0 | | 1 | 3 | | | 0 | 1 | | 1 | 1 | 2 | | | 1 | | | | | | | | | 10 |
| | Loan | 4 | 24 | | 37 | | 24 | 40 | 52 | | 2 | 18 | 25 | | | | | | | 2 | 3 | | | | 230 |
| Global Fund | Grant | 39 | | | | | | | | | | | | | | | | | | | | | | | 39 |
| | Loan | | | | | | | | | | | | | | | | | | | | | | | | |
| EU/EC | Grant | | 39 | 3 | 19 | 2 | 6 | | 0 | 0 | 2 | | 2 | 0 | | 3 | 2 | 0 | | 5 | | | | 0 | 82 |
| | Loan | | | | | | | | | | | | | | | | | | | | | | | | |
| Czech Republic | Grant | 1 | 1 | | 0 | | | 0 | | | 0 | | 0 | | | | 1 | | | | | | | | 3 |
| | Loan | | | | | | | | | | | | | | | | | | | | | | | | |
| France | Grant | 2 | 0 | | 6 | | 0 | 0 | | | 0 | 1 | 0 | 0 | 1 | 2 | | | | 1 | 1 | | | | 14 |
| | Loan | | | | 28 | | 16 | | | | | | | | | | | | | | | | | | 44 |

| Development Partners | Term of Assistance | Health | Education | Social Protection | Agriculture | Manufacturing, Mining & Trade | Rural Development | Bank. & Biz | Urban Plan & Management | Information & Communications | Energy, Power & Electricity | Transportation | Water & sanitation | Comm. & Social | Culture & Arts | Enviro. & Conserv. | Climate Change | Gender | HID/ AIDS | Governance & Administration | Tourism | Budget & BoP Support | Emergency & Food Aid | Others | Total |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| Germany | Grant | 27 | | 3 | 7 | 5 | 5 | 3 | | | | | | | | 1 | 1 | 0 | | 7 | | | | 1 | 59 |
| | Loan | | | | | | | | | | 0 | | | | | | | | | | | | | | 0 |
| Ireland | Grant | 0 | | | | | 1 | | | | | | 0 | | | | | | | | | | | | 2 |
| | Loan | | | | | | | | | | | | | | | | | | | | | | | | |
| Sweden | Grant | 0 | 1 | | 0 | 1 | | 1 | | 0 | | | 0 | | | | | | | 14 | | | | | 17 |
| | Loan | | | | | | | | | | | | | | | | | | | | | | | | |
| Australia | Grant | 10 | 4 | 1 | 11 | 0 | 3 | | | | 2 | | 3 | 2 | | | | 2 | | 3 | | | | 2 | 43 |
| | Loan | | | | | | | | | | | | | | | | | | | | | | | | |
| Canada | Grant | 1 | 0 | | 1 | | | 0 | | | 0 | | | | | 0 | | 0 | | | | | | 1 | 3 |
| | Loan | | | | | | | | | | | | | | | | | | | | | | | | |
